# ជំនឿដ៏ត្រឹមត្រូវ
# និងអ្វីដែលផ្ទុយនឹងជំនឿ

# العقيدة الصحيحة
# ومايضادها

# ជំនឿដ៏ត្រឹមត្រូវ និង អ្វីដែលផ្ទុយនឹងជំនឿនេះ

រៀបរៀងដោយ

អាប់ឌុលអាហ្ស៊ីស ពិន បាស

រ៉ហ៊ីម៉ាហ៊ុលឡោះ

បោះពុម្ពផ្សាយដោយ

សមាគមសម្របសម្រួលសង្គមនៃប្រទេសគូវ៉ែត

សហការជាមួយសមាគមសប្បុរសធម៌ដើម្បីអភិវឌ្ឍន៍កម្ពុជា



بسم الله الرحمن الرحيم

الحمد لله وحده، والصلاة والسلام على من لا نبي بعده وعلى آله وصحبه أجمعين أما بعد:

តាមពិតអាគីឌះសហ៊ីហះ( ជំនឿដ៏ត្រឹមត្រូវ)គឺជាមូលដ្ឋានគ្រឹះនៃសាសនាអ៊ីស្លាម ដូច្នេះខ្ញុំយល់ឃើញថា វាជាប្រធានបទដ៏សំខាន់ដែលត្រូវយកមកបកស្រាយ។ យើងបានដឹងតាមរយៈ(ភស្តុតាង)ផ្នែកខាងសារីអាត់(មាគ៌ាអ៊ីស្លាម)ចេញពីអាល់គួរអាន និងស៊ុណ្ណះថាៈការប្រព្រឹត្តិទាំងអស់ទាំងពាក្យសំដីនិងកាយវិការអាចចាត់ទុកថាត្រឹមត្រូវ និងអាចទទួលយកបានលុះត្រាណាចេញពីអាគីដះដ៏ត្រឹមត្រូវ។ តែបើចេញពីគោលជំនឿមិនត្រឹមត្រូវវិញនោះ គេមិនអាចទទួលយកបានឡើយមិនថាអំពើបែបណានោះទេជាក់ស្តែងដូចពាក្យសំដីអល់ឡោះ មានបន្ទូលថាៈ

(ومن يكفر بالإيمان فقد حبط عمله وهو في الآخرة من الخاسرين ) سورة المائدة الأية 5

មានន័យថាៈ នរណាហើយប្រឆាំងនឹងអ៊ីម៉ាន (ជំនឿដ៏ត្រឹមត្រូវ) នោះពិតប្រាកដអាម៉ាល់(ការសាងអំពើល្អ)របស់គេត្រូវវិនាសអន្តរាយហើយនៅថ្ងៃអាឃីរ៉ោះគេនឹងស្ថិតក្នុងចំណោមពួកអ្នកដែលខាតបង់។អល់ឡោះបានមានបន្ទូលទៀតថាៈ

(ولقد أوحي إليك وإلى الذين من قبلك لئن أشركت ليحبطن عماك ولتكونن من الخاسرين) سورة الزمر/ الآية : 25

មានន័យថាៈពិតប្រាកដគេផ្តល់វ៉ាហ៊ី(បន្ទូលព្រះជាម្ចាស់)ចំពោះឯង ឱមូហាំម៉ាត់! និងរ៉សូលមុនៗអំពីឯងបើសិនជាឯងប្រព្រឹត្តអំពើស៊ីរិកនោះអាម៉ាល់

(ការសាងអំពើល្អរបស់ឯងនឹងត្រូវវិនាសអន្តរាយ ហើយឯងនឹងចូលក្នុងចំណោមអ្នកដែលខាតបង់យ៉ាងពិតប្រាកដ ។ មានកថាខណ្ឌជាច្រើនដែលមានន័យខ្លឹមសារដូចៗគ្នានេះបានបង្ហាញច្បាស់ណាស់នៅក្នុងគីតាប អល់ឡោះ និងស៊ុណ្ណះរ៉ស៊ូលុលឡោះ(ទ្រឹស្តីមាគ៌ារបស់មូហាំម៉ាត់)នៅលើអាគីឌះសហ៊ីហះ ដោយសង្ខេបបង្រួញនៅក្នុងការអ៊ីម៉ាន(ជំនឿ)នឹងអល់ឡោះអ៊ីម៉ាននឹងពពួកម៉ាឡាអ៊ីកាត់អល់ឡោះ -អ៊ីម៉ាននឹងគីតាបអល់ឡោះ -អ៊ីម៉ាននឹងរ៉ស៊ូលៗអល់ឡោះ-អ៊ីម៉ាននឹងថ្ងៃអាឃីរ៉ោះ និងជំនឿលើការសំរេចកំណត់វាសនាល្អ ឬអាក្រក់របស់អល់ឡោះ ។

ទាំងប្រាំមួយប្រការដែលបានរៀបរាប់មកនេះ វាជាឫសគល់នៃ អាគីឌះសហ៊ីហះ(គោលជំនឿដ៏ត្រឹមត្រូវ) ដូចដែលអល់ឡោះបញ្ចុះគម្ពីរ នឹងចាត់តាំងរ៉ស៊ូលក៏អាស្រ័យលើមូលដ្ឋានទាំងប្រាំមួយនេះដែរ ។សាខាដែលទាក់ទងទៅនឹងអ៊ូស៊ូល(ឫសគល់) ទាំងប្រាំមួយនេះដែរគឺចាំបាច់ (វ៉ាជិប) ត្រូវជំនឿលើរឿងរ៉ាវ ឬប្រការៗដែលអាថ៌កំបាំង ។

តាមរយៈភស្តុតាងជាច្រើនដែលអល់ឡោះ និងរ៉ស៊ូលបានបញ្ជាក់ប្រាប់នៅក្នុងគួរអាន និងស៊ុណ្ណះពីអ៊ូស៊ូលទាំងប្រាំមួយនេះ ដូចជាសំដីអល់ឡោះ បានបញ្ជាក់នៅក្នុងរឿងនេះថា:

(ليس البر أن تولوا وجوهكم قبل المشرق والمغرب ولكن البر من آمن بالله واليوم الآخر والملائكة والكتاب والنبيين ) البقرة 177

មានន័យថា: មិនចាត់ទុកថាល្អស្ថិតនៅលើពួកឯងបែរមុខទៅរកទិសខាង



កើត ឬទិសខាងលិចក្នុងរឿងសំពះយ៉ាំងនោះទេ ប៉ុន្តែចាត់ទុកថាល្អនោះគឺស្ថិតនៅលើអ្នកដែលមានជំនឿលើអល់ឡោះ ជឿលើថ្ងៃអាឃីរ៉ោះ (ថ្ងៃបរិលោក) ជំនឿលើពួកម៉ាឡាអ៊ីកាត់ ជំនឿលើគីតាបរបស់អល់ឡោះ (القرآن) និងជំនឿលើពួកណាពីៗ ។ អល់ឡោះបានមានព្រះបន្ទូលថា:

(آمن الرسول بما أنزل إليه من ربه والمؤمنون كل آمن بالله وملائكته وكتبه ورسله لا نفرق بين أحد من رسله ) البقرة :285

មានន័យថា:រ៉ស៊ូលលោកមានជំនឿទាំងស្រុងចំពោះអ្វីៗដែលគេ(អល់ឡោះ) បញ្ចុះលើរូបគេ (ណាពីមូហាំម៉ាត់) ដែលមកពីម្ចាស់របស់គេព្រមទាំងអ្នកមុមិនទាំងអស់សុទ្ធតែមានអ៊ីម៉ានលើអល់ឡោះ។ ជំនឿលើពពួកម៉ាឡាអ៊ីកាត់អ៊ីម៉ានលើគីតាបៗ និងពួករ៉ស៊ូលៗអល់ឡោះដោយគ្មានការបែងចែករវាងរ៉ស៊ូលទាំងនោះឡើយ ។អល់ឡោះបានមានបន្ទូលទៀតថា:

(يا أيها الذين آمنوا آمنوا بالله ورسوله والكتاب الذي نزل على رسوله والكتاب الذي أنزل من قبل ومن يكفر بالله وملائكته وكتبه ورسله واليوم الآخر فقد ضل ضلا بعيدا ) النساء الآية : 137

មានន័យថា:ឱបណ្តាអ្នកមានជំនឿទាំងឡាយ!ចូរមានជំនឿចុះចំពោះអល់ឡោះព្រមទាំងរ៉ស៊ូលរបស់ទ្រង់ និងគីតាបដែលទ្រង់បានបញ្ចុះលើរ៉ស៊ូលនោះថែមទាំងគីតាបដែលគេបញ្ចុះកាលពីមុនៗមក។ ប្រសិនបើនរណាហើយបដិសេធន៍មិនព្រមជឿលើអល់ឡោះលើពពួកម៉ាឡាអ៊ីកាត់លើបណ្តាគីតាបលើបណ្តារ៉ស៊ូលអល់ឡោះហើយមិនមានជំនឿលើថ្ងៃគីយ៉ាម៉ាត់(បរលោក) ទេនោះពិតណាស់អ្នកទាំងនោះបានវង្វេងចាកឆ្ងាយពីផ្លូវដែលត្រឹមត្រូវយ៉ាង

ពិតប្រាកដ។ អល់ឡោះបានមានបន្ទូលដែរថា :

(ألم تعلم أن الله يعلم ما في السماء والأرض إن ذلك في كتاب إن ذلك على الله يسير) الحج :70

មានន័យថា: តើឯងដឹងទេថា? អល់ឡោះមហាជ្រាបដឹងនូវអ្វីដែលមាននៅលើមេឃា និងអ្វីៗដែលស្ថិតនៅលើលោកិយយើងនេះ។ ពិតប្រាកដណាស់រឿងទាំងនេះ គឺមានកំណត់ត្រារួចជាស្រេចនៅក្នុងគីតាបរបស់អល់ឡោះ។ តាមពិតងាយបំផុតសំរាប់អល់ឡោះនៅក្នុងរឿងនេះ។ រីឯហាហ្ទីសដ៏ត្រឹមត្រូវជាច្រើនដែលបានអះអាងលើបណ្តាគោលការណ៏ទាំងនេះ។ ដូចជាហាហ្ទីសសហេស (ត្រឹមត្រូវ) ត្រូវបានគេទទួលស្គាល់ជាទូទៅដែលរាយការណ៏មកដោយអ៊ីមុាំមូស្លីមតាមរយៈហាហ្ទីសអាមៀរុលមុមីនីនអ៊ូម៉ើរ កូនអាល់ខត្តប (رضى الله عنه) ពិតប្រាកដជីបរីលបានសួរណាពីអំពីរឿងអ៊ីម៉ាន (ជំនឿ) ពេលនោះណាពីបានពោលថា:

(الإيمان أن تؤمن بالله وملائكته وكتبه ورسله واليوم الآخر وتؤمن بالقدر خيره وشره)

មានន័យថា: អ៊ីម៉ាននោះគឺអ្នកត្រូវមានជំនឿលើអល់ឡោះ ជំនឿលើពពួកម៉ាឡាអ៊ីកាត់ជំនឿលើគីតាបនិងជំនឿលើបណ្តារ៉ស៊ូលៗអល់ឡោះព្រមទាំងអ្នកត្រូវជឿលើការកំណត់ ឬចំណាវវាសនាល្អ ឬអាក្រក់របស់អល់ឡោះជាម្ចាស់។

ចំពោះបណ្តាគោលការណ៏ទាំងប្រាំមួយនេះដែរ មានប្រការទាំងអស់ដែលទាក់ទង នឹងអ៊ូស៊ូលទាំងប្រាំមួយនេះសុទ្ធតែវ៉ាជិប (ចាំបាច់) លើអ្នក



អ៊ីស្លាមត្រូវអៀកទីកាត់អោយបានច្បាស់លាស់ចំពោះ សិទ្ធិរបស់អល់ឡោះ និងការវិលទៅរកអល់ឡោះវិញ និងរឿងរ៉ាវផ្សេងៗឯទៀតដែលសុទ្ធតែប្រការអាថិកំបាំង (الغيب) ។

**១_អ៊ីម៉ាននឹងអល់ឡោះ**

អ៊ីម៉ាននឹងអល់ឡោះនោះគឺជឿជាក់យ៉ាងពិតប្រាកដថា: អល់ឡោះជាព្រះជាម្ចាស់ពិតប្រាកដដែលសក្តិសមនឹងគោរពធ្វើអ៊ីពើដាត់ហើយគ្មានម្ចាស់ណាផ្សេងក្រៅពីអល់ឡោះពីព្រោះអល់ឡោះទ្រង់ គឺជាម្ចាស់ដែលបង្កើតមនុស្សលោក និងផ្តល់ភាពល្អប្រសើរគ្រប់លក្ខណះចំពោះពួកគេ (មនុស្សលោក) និងជាម្ចាស់ដែលផ្តល់រីស្គីលាភសក្ការៈ (សេចក្តីត្រូវការ) ទាំងការហូបចុក និងវត្ថុផ្សេងៗដែលពួកគេត្រូវការ។ អល់ឡោះជាម្ចាស់មហាជ្រាបដឹងនូវអ្វីដែលពួកគេលាក់នៅក្នុងចិត្ត និងអ្វីដែលពួកមនុស្សប្រព្រឹត្តិជាបើកចំហរ។ អល់ឡោះជាម្ចាស់ដែលមានសមត្ថភាពផ្តល់កុសលបុណ្យ (ប៉ាស់ឡា) ចំពោះការគោរពប្រតិបត្តិតាមរបស់ពួកមនុស្ស ហើយទ្រង់មានសមត្ថភាពគ្រប់គ្រាន់ដើម្បីដាក់ទណ្ឌកម្មចំពោះអ្នកដែលបានប្រព្រឹត្តអំពើម៉ាក់ស៊ីយ៉ាត់(អំពើបាប) នោះដែរ ។ដូច្នេះការគោរពធ្វើអ៊ីពើដាត់ចំពោះអល់ឡោះជាករណីយកិច្ចចំបងបំផុត ពីព្រោះការដែលអល់ឡោះបង្កើតជិន (ព្រាយបិសាច) និងមនុស្សលោកគឺស្ថិតលើករណីអ៊ីពើដាត់នេះឯង។ ដូចអល់ឡោះបានមានព្រះបន្ទូលថា:

(وما خلقت الجن والإنس إلا ليعبدون ما أريد منهم من رزق وما

أريد أن يطعمون إن الله هو الرزاق ذو القوة المتين)
الذاريات 56-57

មានន័យថាៈ យើងបានបង្កើតជិន និងមនុស្សមកគ្មានអ្វីក្រៅពីធ្វើអ៊ិបាដាត់មកចំពោះយើងនោះឡើយ ដោយយើងមិនត្រូវការរិស្គី ឬថ្វាយចំណីអាហារពីពួកគេនោះដែរតាមពិតអល់ឡោះទេដែលជាម្ចាស់ជាអ្នកផ្តល់រិស្គី (សេចក្តីត្រូវការសព្វបែបយ៉ាង) ចំពោះសត្វលោកទាំងឡាយ និងជាម្ចាស់ដែលមានមហិទ្ធិឫទ្ធិខ្លាំងក្លាហួសពីការគិតដល់របស់មនុស្សលោក ។អល់ឡោះបានមានបន្ទូលថាៈ

(يا أيها الناس اعبدوا ربكم الذي خلقكم والذين من قبلكم لعلكم تتقون الذي جعل لكم الأرض فراشا والسماء بناء وأنزل من السماء ماء فأخرج به من الثمرات رزقا لكم فلا تجعلوا لله أندادا وأنتم تعلمون)

មានន័យថាៈ នែ! មនុស្សលោកទាំងឡាយចូរពួកឯងប្រតិបត្តិអ៊ិបាដាត់ចុះទៅចំពោះម្ចាស់ដែលបង្កើតពួកឯង និងបង្កើតអ្នកជំនាន់មុនពួកឯង សង្ឃឹមថាពួកឯងនឹងមានសេចក្តីកោតខ្លាចចំពោះម្ចាស់ដែលជាអ្នកបង្កើតពួកឯងទាំងអស់គ្នា និងផែនដីដែលលាតសន្ធឹង និងមេឃាជាសំណង់សង់ពីលើថែមទាំងបានបញ្ចុះពីលើមេឃមកនូវទឹកភ្លៀង ហើយបានបញ្ចេញតាមរយៈទឹកភ្លៀងនូវភោគផលផ្លែផ្កា។ ទាំងអស់នេះគឺជារិស្គីសំរាប់ពួកឯង ប៉ុន្តែពួកឯងគប្បីកុំបង្កើតម្ចាស់ផ្សេងទៀតដើម្បីធ្វើអ៊ិបាដាត់រួមជាមួយអល់ឡោះ(ស៊ីរិក) អោយសោះក្នុងខណៈដែលអ្នកទាំងអស់គ្នាយល់ដឹងអំពីស៊ីរិកនេះ ។



ពិតប្រាកដណាស់អល់ឡោះបានបបញ្ជូនរ៉ស៊ូល១ជាច្រើន និងបានបញ្ចុះគីតាប(គម្ពីរ) ដើម្បីបញ្ជាក់លើការពិត និង ដើម្បីដាក់វ៉ះ(អំពាវនាវ) ទៅរកអល់ឡោះតែមួយគត់ និងជៀសវាងនូវអ្វីដែលផ្ទុយពីប្រការទាំងនេះ ជាក់ស្តែងដូចអល់ឡោះបានមានបន្ទូលថាៈ

(ولقد بعثنا في كل أمة رسولا أن اعبدوا الله واجتنبوا الطاغوت) النحل 36

មានន័យថាៈ ពិតប្រាកដយើងបានចាត់តាំងរ៉ស៊ូលម្នាក់ ទៅគ្រប់១ជំនាន់ដើម្បីរ៉ស៊ូលទាំងនោះបានប្រើពួកអ៊ូម៉ាត់(ប្រជាជន) របស់គេធ្វើអ៊ិបាដាត់ទៅចំពោះអល់ឡោះតែមួយគត់ និងអោយពួកគេបញ្ចៀសអំពីការធ្វើអ៊ិបាដាត់ទៅចំពោះតហ្គោត(អ្វីដែលគេបូជាក្រៅពីអល់ឡោះ) ។

## ***ហាគីកាត់ ( ធាតុពិត) នៃអ៊ិបាដាត់***

គឺរាល់ការគោរពបូជារបស់ខ្ញុំអល់ឡោះនោះគឺតំរង់ទៅរកអល់ឡោះតែមួយគត់គិតទាំងការសុំឌូអា ការកោតខ្លាច ការសង្ឃឹម រំពឹង ការសឡាសការបួស ការសំឡេះសត្វបូជា និងអ៊ិបាដាត់ផ្សេង១ទៀតសុទ្ធតែទាមទារអោយមានភាពអោនលំទោន និងសង្ឃឹមជឿជាក់ចំពោះរ៉ស់ម៉ាត់ (ក្តីមេត្តាករុណា) ពីអល់ឡោះ ព្រមទាំងខ្លាចទណ្ឌកម្មរបស់ទ្រង់ ថែមទាំងពេញចិត្តនឹងអល់ឡោះ ដោយភាពអោនលំទោនចំពោះអំណាច និងភាពធំធេងរបស់ទ្រង់ ។

ភាគច្រើនគួរអានបានបញ្ចុះមកដើម្បីបញ្ជាក់ពីមូលដ្ឋានដ៏ធំនេះ(តាវហេតុ) ដូចអល់ឡោះបានមានព្រះបន្ទូលថាៈ

(فاعبدوا الله مخلصا له الدين ألا لله الدين الخالص) الزمر 2-3

មានន័យថាៈចូរពួកឯងគោរពធ្វើអ៊ីពើដាត់ទៅចំពោះអល់ឡោះដោយស្មោះស្ម័គ្រជ្រះថ្លាតាមគន្លងនៃសាសនា ពោលគឺតាមអាល់គួរអាន និងស៊ុណ្ណះ ចូរជ្រាបអោយច្បាស់ថាសំរាប់អល់ឡោះនោះគឺសាសនាដែលស្អាតស្អំបំផុត ។

អល់ឡោះបានមានបន្ទូលថាៈ

(وقضي ربك أن لا تعبدوا إلا إياه)

មានន័យថាៈ ម្ចាស់របស់ឯង محمد បានសំរេចដាច់ខាតមិនអោយអ្នកឯងគោរពធ្វើអ៊ីពើដាត់ទៅចំពោះអ្នកណាក្រៅពីអល់ឡោះឡើយ ។

អល់ឡោះមានបន្ទូលទៀតថា[3]

(فادعوا الله مخلصين له الدين ولو كره الكافرون)

មានន័យថាៈចូរពួកឯងឌូអាទៅចំពោះអល់ឡោះដោយចិត្តជ្រះថ្លាតាមគន្លងនៃសាសនាអ៊ិស្លាម ពោលគឺតាមអាល់គួរអាន និងហាហ្ទីសសូម្បីមានការតិះដៀលពីសំណាក់ពួកកាហ្វៀរក៏ដោយ ។ មានហាហ្ទីសដ៏ត្រឹម ត្រូវចេញពីមូអាស (رضي الله عنه) ពិតប្រាកដបានពោលថាៈ

(حق الله على العباد أن يعبدوه ولا يشركوا به شيئا)

មានន័យថាៈ កាតព្វកិច្ចដាក់លើខ្ញុំរបស់ទ្រង់នោះ គឺពួកគេគោរពបូជាចំពោះអល់ឡោះដោយគ្មានអំពើស៊ីរិកណាមួយមករួមជាមួយក្នុងការធ្វើអ៊ីពើដាត់ទៅចំពោះអល់ឡោះនោះឡើយ ។

## អំពីជំនឿនឹងអល់ឡោះនោះទៀត

គឺជំនឿទាំងអស់នូវអ្វីដែលអល់ឡោះដាក់វ៉ាជិប និងហ្វើរឌូ(បង្គាប់)ទៅលើ



រាល់ៗបុគ្គល ដូចមាននៅក្នុងរូកុន(មូលដ្ឋានគោល) អ៊ីស្លាមទាំងប្រាំប្រការ ។ នោះគឺត្រូវអះអាងទាំងពាក្យសំដីនិងចិត្តគំនិតថាពិតប្រាកដគ្មានទេម្ចាស់ក្រៅពីអល់ឡោះនិងមូហាំម៉ាត់នោះជារ៉ស៊ូលអល់ឡោះប្រតិបត្តិសឡាស បួសខែរ៉ម៉ាដន បរិច្ចាគទ្រព្យសម្បត្តិដល់ជនក្រីក្រ និងទៅធ្វើរូកុនហាជ្ជី(បុណ្យហាជ្ជី) នៅប៉ៃតុលឡោះអាល់ហារ៉ម(ចំពោះអ្នកដែលមានលទ្ធភាពគ្រប់គ្រាន់)និងផ្សេងៗទៀតអំពីហ្វើរឌូទាំងឡាយ ដែលផ្តល់ដោយសារីអាត់ (ច្បាប់) ដ៏បរិសុទ្ធ ។ ចំណុចដែលសំខាន់ជាងគេបំផុតក្នុងចំណោមរូកុនអ៊ីស្លាម ទាំងប្រាំនេះគឺត្រូវអះអាងធ្វើសាក្សីថា ពិតប្រាកដគ្មានទេម្ចាស់ក្រៅពីអល់ឡោះ និងពិតប្រាកដមូហាំម៉ាត់ នោះជារ៉ស៊ូលអល់ឡោះព្រោះសើហាដះ(ការធ្វើសាក្សី) នេះធ្វើអោយ អៀសក្លើស(ភាពស្មោះត្រង់) មានចិត្តជ្រះថ្លាក្នុងការធ្វើអ៊ីពើដាត់ទាំងឡាយទៅចំពោះអល់ឡោះតែមួយគត់ ហើយត្រូវបដិសេធទាំងអស់នូវម្ចាស់ទាំងឡាយណាដែលផ្សេងពីអល់ឡោះ ។ ឯអត្ថន័យនៃកាលីម៉ះមានន័យថាៈ គ្មានទេអ្នកដែលត្រូវគោរពបូជាពិតប្រាកដក្រៅពីអល់ឡោះដូច្នេះអ្វីដែលគេគោរពក្រៅពីអល់ឡោះ ដូចជាបូជាចំពោះមនុស្សលោក ម៉ាឡាអ៊ីកាត់ ព្រាយបិសាចសុទ្ធតែនាំអោយចេញពីអ៊ីស្លាមទាំងអស់ សរុបសេចក្តីមកម្ចាស់ដែលត្រូវគោរពធ្វើអ៊ីពើដាត់ពិតប្រាកដនោះគឺអល់ឡោះតែមួយគត់ ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា :

(ذلك بأن الله هو الحق وأن ما يدعون من دونه هو الباطل)

មានន័យថាៈ ពិតហើយក្នុងរឿងដូច្នោះអល់ឡោះ គឺជាម្ចាស់ដ៏ពិតប្រាកដ

ហើយអ្វីៗដែលពួកគេបួងសួងសុំក្រៅពីអល់ឡោះ សុទ្ធតែមិនត្រឹមត្រូវទាំងអស់។ ដូចបានបញ្ជាក់នៅខាងដើមរួចមកហើយថា គោលបំណងដែលអល់ឡោះបង្កើតទាំងពីរប្រភេទ (ជិន និង មនុស្ស) គឺដើម្បីអោយពួកគេគោរពប្រណិបត្តិទៅចំពោះអល់ឡោះតែមួយគត់។ ការដែលអល់ឡោះបានបញ្ជូនរ៉ស៊ូលទាំងអស់ និងបញ្ចុះគីតាបៗក៏ដើម្បីអំពាវនាវដោយចង្អុលបង្ហាញទៅរកអ៊ីពើដាត់ (ការគោរពសក្ការៈ) ដែលជាប្រភពដើមនៃការបង្កើតមនុស្ស និងជិន(ព្រាយបីសាច)ទាំងអស់នោះដែរ។ចូរអ្នកពិចារណាអោយបានល្អិតល្អន់ និងតាមដានអោយបានដិតដល់ទើបអ្នកអាចយល់ច្បាស់ក្នុងបញ្ហានេះ និងមិនអាចធ្លាក់ទៅក្នុងអ្វីដែលមិនច្បាស់លាស់ដូចមនុស្សខ្លះដោយភាពងងឹតងងុលមិនបានដឹងច្បាស់ពី (អាល់អាស៊ូលអាល់អាស៊ិល) រហូតយកម្ចាស់ផ្សេងគោរពធ្វើអ៊ីពើដាត់រួមនឹងអល់ឡោះ និងបែងចែកអ៊ីពើដាត់ដ៏ជ្រះស្អាតច្បាស់លាស់ពិតប្រាកដរបស់អល់ឡោះសំរាប់វត្ថុផ្សេងទៀត។

## អំពីជំនឿ(អ៊ីម៉ាន)នោះដែរ

គេត្រូវជឿថា: ពិតប្រាកដអល់ឡោះគឺជាម្ចាស់បង្កើតពិភពលោក ហើយជាអ្នកតាមដានត្រួតពិនិត្យគ្រប់កិច្ចការរបស់ពួកគេ និងជាអ្នកចាត់ចែងគ្រប់រឿងរ៉ាវទាំងអស់របស់ពួកគេដោយគតិស្វែងយល់ និងសមត្ថភាពរបស់អល់ឡោះតាមបំណងរបស់ទ្រង់ ហើយពិតប្រាកដណាស់ទ្រង់ជាម្ចាស់ដែលត្រួតត្រាលោកយើងនេះ និងលោកខាងមុខ ហើយម្ចាស់នៃពិភពលោកទាំងអស់ដែលគ្មានម្ចាស់ណាបង្កើត ឬគ្រប់គ្រងក្រៅពីអល់ឡោះនោះឡើយ



ហើយអល់ឡោះជាអ្នកដែលបានបញ្ជូនរ៉ស៊ូលទាំងអស់ និងបញ្ចុះគម្ពីរដើម្បីកែសំរួលខ្ញុំអល់ឡោះ និងអំពាវនាវពួកគេទៅរកសេចក្តីសុខក្នុងលោកយើងនេះនិងលោកខាងមុខ និងស្អាតស្អំប្រសើររហូតដល់សូន្យសង្ខារ។

ដូចអល់ឡោះ បានមានបន្ទូលថា:

( إن ربكم الله الذي خلق السموات والأرض في ستة أيام ثم استوى على العرش ) الأعراف 54

មានន័យថា:ពិតប្រាកដម្ចាស់របស់ពួកឯងនោះគឺអល់ឡោះ ដែលជាម្ចាស់បង្កើតប្រាំពីរជាន់មេឃនិងដីក្នុងរយៈពេលប្រាំមួយថ្ងៃក្រោយមកអល់ឡោះ(الإستواء)នៅលើអារ៉ស ។

## ប្រការដែលត្រូវជឿនោះទៀត

គឺជឿនឹងព្រះនាមរបស់អល់ឡោះជាម្ចាស់ដ៏ល្អថ្លៃថ្លាក្រៃលែង និងលក្ខណៈសម្បត្តិរបស់អល់ឡោះដ៏មហាខ្ពង់ខ្ពស់បំផុត ដែលបានបញ្ជាក់ប្រាប់តាមរយៈគម្ពីរអាល់គូរអាន និងតាមការបញ្ជាក់ប្រាប់ពីសំណាក់រ៉ស៊ូលអល់ឡោះដោយមិនអាចកែប្រែបាន(تحريف)ហើយមិនអាចតាក់ទីល(تعطيل) បានន័យថា:អល់ឡោះនោះមាន តែគ្មានសកម្មភាពអ្វីទាំងអស់ ឬគ្មានចលនាអ្វីទាំងអស់ឬទៅជាមិនមានវិញ។ ហើយក៏មិនអាចតឹកយីហ្វ (تكييف) ដោយថា(ស៊ីហ្វាត)លក្ខណៈអល់ឡោះមានយ៉ាងនេះឬយ៉ាងនោះដូចជាឈរអង្គុយ ឬផ្សេងៗទៀត។ ឬក៏មិនអាច (تمثيل) ប្រដូចអល់ឡោះទៅនឹងអ្វីមួយ។ ផ្ទុយទៅវិញចាំបាច់ត្រូវដើរតាមអ្វីៗដែលផ្តល់តាមរយៈគូរអាន និង


- 11 - - 11 -

ហាហ្វីស ដោយគ្មានការដេញដោលយ៉ាងនេះ ឬយ៉ាងនោះឡើយ ។ ហើយជឿនូវអ្វីដែលចង្អុលប្រាប់ទៅតាមន័យខ្លឹមសារពិតប្រាកដនៃ (ស៊ីហ្វាត) លក្ខណៈសម្បត្តិរបស់អល់ឡោះទាំងឡាយ និងចាំបាច់ត្រូវជឿជាក់ថា លក្ខណៈសម្បត្តិ ដែលអល់ឡោះបានប្រាប់មកគឺពិតជាមានដូច្នោះមែន ។ តែសក្តិសមសំរាប់អល់ឡោះលើ(ស៊ីហ្វាត)ទាំងនោះ ដោយមិនអាចយកទៅប្រៀបប្រដូចនឹងធម្មជាតិដែលអល់ឡោះបង្កើតបានឡើយ ។ ដូចអល់ឡោះបានមានបន្ទូលថា:

(ليس كمثله شيء وهو السميع البصير)

មានន័យថា: គ្មានទេការប្រៀបប្រដូចអល់ឡោះទៅនឹងអ្វីមួយ ហើយអល់ឡោះនោះមានលក្ខណៈមហាឮ និងមហាឃើញ។ អល់ឡោះមានបន្ទូលទៀតថា:

(فلا تضربوا لله الأمثال إن الله يعلم وأنتم لا تعلمون)

មានន័យថា: ចូរពួកឯងកុំយកអល់ឡោះប្រដូចទៅនឹងអ្វីមួយអោយសោះ ពិតប្រាកដអល់ឡោះដឹងនូវអ្វីដែលពួកឯងមិនបានដឹង ។ទាំងនោះគឺជាគោលជំនឿរបស់អះលីស៊ុណ្ណះវ៉ាល់ជើម៉ាអះ(ក្រុមមនុស្សដើរតាមមាគ៌ារបស់ណាពីមូហាំម៉ាត់ដោយឥតលំអៀង) ដែលជាជំនឿរបស់គូរកន (សហាហ្ពាត់) របស់រ៉ស៊ូលុលឡោះ និងជាជំនឿរបស់អ្នកបន្ទាប់ពីគូកនរបស់ណាពីផងដែរ ដែលគេហៅថា(តេពីអ៊ីន)ក៏ដូចជាគោលជំនឿទទួលចំលងតាម(ប្រតិបត្តិ) នៃលោកអ៊ីមុាំឪពុករបស់ហាសាន់អាល់អាស់អារី ពិសេសមាននៅក្នុងគីតាប



របស់គាត់ឈ្មោះ (المقالات عن أصحاب الحديث وأهل السنة)និងអ្នកផ្សេងៗទៀតនៃសាសនវិទូអ៊ីស្លាមដូចប្រសាសន៍របស់សាសនវិទូអ៊ូសាអ៊ីថា:មានគេសួរទៅឈ្មោះអាល់ស៊ះរី និងម៉ឹកហ៊ូលអំពីកថាខណ្ឌរបស់គូរអាននិយាយអំពីលក្ខណៈសម្បត្តិរបស់អល់ឡោះ គាត់ទាំងពីរបានឆ្លើយថា:ត្រូវឯកភាពទទួលស្គាល់ដូចអ្វីដែលផ្តល់មកក្នុងកថាខណ្ឌនោះ ។

អាល់វ៉ាលីតពិនមូស្លីមក៏បានពោលថា:មានគេសួរម៉ាលិក និង អាល់អ៊ូសាអ៊ី អាល់ឡៃស ពិនសាអាត់ និងសាហ្វយ៉ាន អាល់ស៊ូរី អំពីរឿងដែលទាក់ទងនឹងលក្ខណៈសម្បត្តិរបស់អល់ឡោះ ពួកគេទាំងអស់ឆ្លើយដូចៗគ្នាថា: ត្រូវឯកភាពជឿតាមដូចអ្វី ដែលអល់ឡោះបានផ្តល់មកតាមរយៈគូរអានដោយគ្មានការដេញដោលថាយ៉ាងដូចម្តេចនោះឡើយ ។

អាល់អ៊ូសាអ៊ីបានមានប្រសាសន៍ថា:មានជំនឿតាមតាពីអ៊ីន (អ្នកដែលរស់នៅទាន់សម័យគូកនរបស់ណាពី)ដ៏ច្រើនដែលនាំគ្នាថា: ពិតប្រាកដអល់ឡោះស្ថិតនៅលើអារ៉ស(عرش)នោះ ហើយពួកយើងជឿនូវអ្វីដែលបាននាំមកដោយរ៉ស៊ូលុលឡោះ ។

អាល់អ៊ូសាអ៊ី បានមានប្រសាសន៍ថា:ពួកយើងនឹងតាមតាពីអ៊ីនដ៏ច្រើនដែលមានប្រសាសន៍ថា: ពិតប្រាកដអល់ឡោះស្ថិតនៅលើអារ៉ស្ស(عرش) នោះហើយពួកយើងត្រូវមានជំនឿដូចអ្វីដែលបានផ្តល់តាមរយៈស៊ុណ្ណះដែលបានប្រាប់ពីបណ្តាស៊ីហ្វាតរបស់អល់ឡោះទាំងអស់ ។ ត្រូវគេសួរ រ៉ពីអះ កូន

របស់ អាប់ឌុរ៉ស់ម៉ាន សៀខម៉ាលិកអំពីពាក្យ អ៊ិស្ទីវ៉ាក (الاستواء) គាត់បានឆ្លើយថា:

(الاستواء غير مجهول والكيف غير معقول ومن الله الرسالة وعلى الرسول البلاغ المبين وعلينا التصديق)

មានន័យថា: ពាក្យថាអ៊ិស្ទីវ៉ាកមិនមែនមិនយល់នោះទេ គឺគេចង់និយាយន័យ(الاستواء)វាដូចដែលគេដឹងតាមន័យពិតរបស់វាដូច្នោះឯង តែយ៉ាងដូចម្តេចនោះយើងមិនអាចដឹងតាមរយៈការគិតរបស់យើងបានទេ។ សំរាប់អល់ឡោះនោះបញ្ជូនរីសាឡះ(បញ្ជូនសារ) ហើយចំពោះរ៉ស៊ូលុលឡោះជាអ្នកផ្តល់រីសាឡះ(រឿងរ៉ាវសាសនា) សំរាប់យើងទាំងអស់គ្នាត្រូវទទួលស្គាល់អ្វីៗដែល បានផ្តល់មកតែប៉ុណ្ណោះ។ ខណៈដែលគេសួរអ៊ីមុាំម៉ាលិកអំពីរឿងនេះគាត់មានប្រសាសន៍ថា:

( الاستواء معلوم والكيف مجهول والإيمان به واجب والسؤال عنه بدعة )

បានន័យថា: អាល់អ៊ិស្ទីវ៉ាក (الاستواء)ដូចយើងជ្រាបស្រាប់ន័យរបស់វា ហើយអាល់កៃហ្វា (الكيف) យ៉ាងណានោះយើងមិនអាចដឹងបានទេ ហើយជំនឿលើរឿងនោះ វាជាកាតព្វកិច្ចត្រូវតែជឿហើយសួរដេញដោលអំពីរឿងនេះគឺពិតអះ បន្ទាប់មក អ៊ីមុាំម៉ាលិកបានពោលទៅកាន់អ្នកដែលសួរនោះថា: យើងមើលទៅអ្នកមិនមែនជាមនុស្សល្អនោះឡើយ ក្រោយមកគាត់ក៏បណ្តេញអោយត្រឡប់ទៅវិញ។អ៊ីមុាំអាប់ឌុរ៉ស់ម៉ាន អាប់ឌុលឡោះ កូនរបស់អាល់មូពើរ៉ុក បានមានប្រសាសន៍ថា: យើងទទួលស្គាល់ថាម្ចាស់របស់យើងពិតជានៅលើមេឃលើអារ៉ស្សរបស់ទ្រង់ដោយឃ្លាតឆ្ងាយពីការប្រៀប



ប្រដូចទៅនឹងអ្វីៗដែលទ្រង់បានបង្កើត។

ទ្រឹស្តីរបស់អ៊ីមុាំជាច្រើនបានបញ្ជាក់ក្នុងជំពូកនេះដោយមិនអាចបកស្រាយក្នុងសៀវភៅតូចនេះអោយបានពិស្តារឡើយ បើចង់ជ្រាបច្បាស់ត្រូវត្រឡប់ទៅរកគីតាបអិស្ស៊ុណ្ណះរបស់លោក អាប់ឌុលឡោះ កូនអ៊ីមុាំអះម៉ាត់ និងគីតាបផ្សេងៗទៀត ។

## រីឯអះលុស្ស៊ុណ្ណះវ៉ាល់យើម៉ាអះ

ពួកគេអះអាងបញ្ជាក់លើអល់ឡោះ ដូចអ្វីដែលអល់ឡោះខ្លួនឯងផ្ទាល់បានអះអាងលើខ្លួនទ្រង់ក្នុងគីតាប (អាល់គូរអាន) ហើយរ៉ស៊ូលុលឡោះក៏បានបញ្ជាក់ដូច្នោះដែរក្នុងហាហ្ទីសរបស់គាត់ ដ៏ពិតប្រាកដដែលជ្រះស្អាតអំពីការប្រៀបប្រដូចអល់ឡោះទៅនឹងអ្វីៗទាំងឡាយ ដែលអល់ឡោះជាអ្នកបង្កើតនោះទេ ហើយក៏គ្មានការតាក់ទីល (التعطيل) នោះដែរ។ ដូច្នោះអ្វីដែលធ្វើអោយពួកគេទទួលបានជ័យជំនះចាកផុតអំពីអ្វីៗ ដែលធ្វើអោយគេក្លាយជាអសាបង់ ហើយពួកគេប្រតិបត្តិទាំងអស់នៅក្នុងសាសនាគឺត្រូវតែមានភស្តុតាងជានិច្ច។ នេះជាមាគ៌ារបស់អល់ឡោះ សំរាប់អ្នកដែលឈរលើការពិត ហើយអល់ឡោះបានបង្កើតរ៉ស៊ូលទាំងអស់ក៏ឈរលើមាគ៌ាដ៏ត្រឹមត្រូវនេះដែរ ដូច្នេះគឺត្រូវជ្រះថ្លាចំពោះអល់ឡោះនូវអ្វីដែលគេសុំពីអល់ឡោះដើម្បីអោយស្របតាមការពិតនិងច្បាស់លាស់ និងត្រឹមត្រូវ។ អាល់ហាហ្ទីសអ៊ិបនូកាសៀវ បានលើកឡើងក្នុងការបកស្រាយដ៏ល្បីល្បាញរបស់គាត់ នៅក្នុងអាល់

គួរអានត្រង់ ចំនុចពាក្យសំដីរបស់អល់ឡោះដែលបានលើកឡើងថា:

( إن ربكم الله الذي خلق السموات والأرض في ستة أيام ثم استوى على العرش )

ដោយគាត់មានប្រសាសន៍ថា: សំរាប់មនុស្សជាច្រើននៅត្រង់ចំនុចនេះដែលបញ្ចេញយោបល់ជជែកវែកញែក ដែលមិនជ្រះស្រឡះ។ តែត្រង់ចំនុចនេះមិនត្រូវវែកញែកអោយវែងឆ្ងាយនោះទេ ការពិតយើងត្រូវដើរតាមគន្លងនៃម៉ាសហ៊ាបសាឡាហ្វអើស្សសោឡេះ (السلف الصالح) (អ្នកជំនាន់ដើមដែលអនុវត្តតាមមាគ៌ាអ៊ីស្លាមដ៏ស្អាតស្អំ) ដូចជាអ៊ីមាំម៉ាលិកអាវសាអ៊ីអើសស្ហ៊ីរីអាល់លែស ពិនសាអាត់ សាហ្វីអ៊ី អ៊ិស្ហាកពិនរ៉ហារីយ៉ះ អះម៉ាត់ព្រមទាំងអ៊ីមាំផ្សេងៗទៀត ទាំងជំនាន់មុន និងជំនាន់ថ្មីនេះ។ ចំពោះខ្លួនគាត់ផ្ទាល់ ក៏ដើរតាមនូវអ្វីដែលអាយ៉ាត់នេះបានផ្តល់មកនោះដែរ ដោយគ្មានដេញដោលជជែកថាយ៉ាងម៉េចនោះឡើយ ឬក៏គ្មានការប្រដូច(تمثيل) អល់ឡោះ ទៅនឹងអ្វីទាំងអស់ ហើយក៏គ្មាន (التعطيل) ទៅនឹងអ្វីទាំងអស់សរុបមកថា រាល់អ្វីៗទាំងអស់សុទ្ធតែបដិសេធពីការប្រៀបប្រដូចអល់ឡោះទៅនឹងអ្វីៗ ដែលទ្រង់បង្កើតនោះ។ ដូចជាណាអ៊ីម ពិនមូហាំម៉ាត់ អាល់ខហ៊្សាអ៊ី អ៊ីមាំពូ ខរី និងអ៊ីមាំផ្សេងៗទៀតបាន មានប្រសាសន៍ថា :

(من شبه الله بخلقه كفر، ومن جحد ما وصف الله به نفسه فقد كفر ، وليس فيما وصف الله به نفسه ولا رسوله تشبيه ، فمن أثبت لله تعالى ما وردت به الآيات الصريحة والأخبار الصحيحة على الوجه الذي يليق بجلال الله ونفي عن الله تعالى النقائص فقد سلك سبيل الهدى)



មានន័យថា: នរណាហើយប្រដូចអល់ឡោះទៅនឹងមេីខ្លោក(ធម្មជាតិ) អ្នកនោះនឹងក្លាយទៅជាកាហ្វៀរ ហើយនរណាប្រឆាំងនឹងអ្វីដែលអល់ឡោះពណ៌នាប្រាប់ចំពោះខ្លួនឯងពិតប្រាកដអ្នកនោះ ក៏ក្លាយទៅជាកាហ្វៀរដែរ។ អ្វីៗដែលអល់ឡោះ និង រ៉សូលអល់ឡោះបានពណ៌នានោះ គឺមិនអាចប្រៀបប្រដូច ឬកែប្រែខ្លឹមសារបានឡើយ។ ហើយនរណាអះអាងជឿជាក់ចំពោះអល់ឡោះ តាមអ្វីដែលបានបញ្ជាក់ក្នុងអាយ៉ាត់ដ៏ច្បាស់លាស់ និង ហាទេសដ៏ត្រឹមត្រូវទៅលើផ្លូវដែលសក្តិសមខ្ពង់ខ្ពស់របស់អល់ឡោះ និង បដិសេធពីអល់ឡោះនូវភាពខ្វះខាតមិនគ្រប់លក្ខណៈនោះអ្នកនោះហើយជា អ្នកដែលដើរតាមផ្លូវចង្អុលបង្ហាញពីអល់ឡោះដ៏ពិតប្រាកដ(سبيل الهدى)។

## ២-ជំនឿនឹងម៉ាឡាអ៊ីកាត់

ត្រូវជំនឿនឹងពពួកម៉ាឡាអ៊ីកាត់ដោយសរុបរួមទាំងអស់ ទោះបីបានឬមិនបានបកស្រាយពណ៌នាអំពីពួកគេនៅក្នុងគួរអាននិងហាហ្ទីសក៏ដោយ។

❈ចំពោះអ្នកអ៊ីស្លាមត្រូវជឿថា:សំរាប់អល់ឡោះមានពួកម៉ាឡាអ៊ីកាត់ដែលអល់ឡោះបង្កើតពួកគេដើម្បីគោរពតាមអល់ឡោះ និងអល់ឡោះផ្តល់អោយពួកគេនូវស៊ីហ្វាត(លក្ខណៈ)ដ៏ប្រសើរតែពួកគេមិនអាចដឹងជាមុននូវអ្វីដែលនឹងកើតឡើងនោះទេ អំពីកិច្ចការអល់ឡោះនោះ ហើយពួកគេបំពេញកិច្ចការអល់ឡោះនិងគោរពប្រតិបត្តិចំពោះអល់ឡោះ។

❈ពួកម៉ាឡាអ៊ីកាត់នោះ គឺមានចំនួនក្រុមទៅតាមផ្នែក ពួកខ្លះមានតួនាទីជាអ្នកទ្រអារ៉ស្ស ពួកគេខ្លះមានតួនាទីយាមទ្វារឋានសួគ៌ និងឋាននរក និងពួកខ្លះទៀតមានតួនាទីកត់ត្រានូវអំពើល្អ និងអំពើអាក្រក់របស់មនុស្សលោក។

 - 17 - - 17 - 

យេីងត្រូវជឿម៉ាឡាអ៊ីកាត់ តាមរបៀបរាយការណ៏លំអិតដែលអល់ឡោះ និងរ៉សូ៊លអល់ឡោះបានប្រាប់ឈ្មោះរបស់ពួកគេ។ ពួកគេទាំងនោះមានដូចជាជីពរីល(جبريل) មីកាអេល(ميكائيل) ម៉ាលិកហ្សាពេនីយ៉ះ(مالك زبانية) អ៊ីសរ៉ហ្វេល(إسرافيل) ដែលមានតួនាទីជាអ្នកផ្លុំត្រែនៅថ្ងៃគីយ៉ាម៉ាត់(ថ្ងៃបរលោក) ហេីយមានហាហ្ទីស៧ជាច្រេីន ដែលបញ្ជាក់ប្រាប់ពិសេសដូចបានអះអាងក្នុងហាហ្ទីសអាអ៊ីសះដ៏ត្រឹមត្រូវនេះ។ ពិតប្រាកដរ៉សូ៊លុលឡោះបានមានប្រសាសន៏ថា:

قال رسول الله صلى الله عليه وسلم ( خلقت الملائكة من نور خلق الجان من مارج من نار وخلق آدم مما وصف لكم) أخرجه مسلم في صحيحه.

មានន័យថា:គេបង្កេីតពួកម៉ាឡាអ៊ីកាត់នោះអំពីធាតុពន្លឺហេីយគេបង្កេីតពួកជិន(ព្រាយបីសាច) អំពីអណ្តាតភ្លេីង និងគេបង្កេីតណាពីអាឌាំដូចលក្ខណៈរបស់ពួកឯងគឺ អំពីធាតុដី។

## ៣_ជំនឿនឹងបណ្តាគម្ពីររបស់អល់ឡោះ

ចាំបាច់លេីយេីងជំនឿរួមថា ពិតប្រាកដអល់ឡោះបានបញ្ចុះគម្ពីរមកលេីណាពី និងរ៉សូ៊លរបស់អល់ឡោះ គឺដេីម្បីបញ្ជាក់នូវធាតុពិតរបស់អល់ឡោះ និងដេីម្បីអំពាវនាវទៅរកអល់ឡោះ ដូចអល់ឡោះមានបន្ទូលថា:

(كان الناس أمة واحدة فبعث الله النبيين مبشرين ومنذرين وأنزل معهم الكتاب وبالحق ليحكم بين الناس فيما اختلفوا فيه ) البقرة

មានន័យថា: ពិតហេីយមនុស្សនោះជាអ៊ូម៉ាត់(ប្រជាជន)តែមួយ



ហេីយអល់ឡោះបានបង្កេីតណាពី៧ដែលផ្តល់ដំណឹងអាក្រក់ ឬគំរាមចំពោះពួកកាហ្វៀរ ហេីយអល់ឡោះបញ្ចុះអោយណាពីទាំងនោះនូវគម្ពីរដែលនាំមកនូវការពិតដេីម្បីសំរេចច្បាប់ ឬវែកញែករវាងអ្វីដែលមនុស្សនៅខ្វែងគំនិតគ្នាក្នុងរឿងនោះ។ យេីងត្រូវជឿនឹងគម្ពីរ ដែលអល់ឡោះបានបញ្ចុះមកមានដូចជាតៅរ៉ត(التوراة) អ៊ីញជីល(الإنجيل) ហ្ស៊ាពូរ(الزبور) និងគម្ពីរគូរអាន(القرآن)។ ក្នុងចំនោមគម្ពីរទាំងអស់ដែលប្រសេីរជាងគេ គឺគម្ពីរគូរអានដែលជាគម្ពីរចុងក្រោយហេីយក៏បានបកស្រាយបញ្ជាក់ការពិតចំពោះគម្ពីរមុន៧ផងដែរ។ ហេីយចាំបាច់សំរាប់ប្រជាជនទាំងអស់ត្រូវដេីរតាម និងកាត់ក្តីស្របទៅតាមគម្ពីរគូរអាន ទន្ទឹមនឹងហាហ្ទីសដែលជាស៊ុណ្ណះរបស់រ៉សូ៊លុលឡោះ ពីព្រោះអល់ឡោះបង្កេីតរ៉សូ៊លរបស់ទ្រង់មូហាំម៉ាត់ជារ៉សូ៊លទៅកាន់ជិន និងមនុស្សលោកទាំងអស់ហេីយអល់ឡោះបានបញ្ចុះអាល់គូរអាននេះគឺសំរេចច្បាប់ឬវែកញែករវាងពួកគេទាំងអស់។ ហេីយអល់ឡោះបានបញ្ចុះអាល់គូរអាននេះដែរ គឺជាឱសថដ៏សក្តិសិទ្ធសំរាប់ព្យាបាលអ្វី៧គ្រប់យ៉ាង ដែលមាននៅក្នុងទ្រូងរបស់មនុស្សហេីយអ្វី៧គ្រប់យ៉ាងទាំងអស់សុទ្ធតែបានបញ្ជាក់ប្រាប់នៅក្នុងគម្ពីរអាល់គូរអាន។ អាល់គូរអានគឺសំរាប់ផ្តល់ពន្លឺនៃផ្លូវត្រូវ និងសំរាប់អ្នកដែលមានជំនឿគ្រប់រូបដូចអល់ឡោះ បានមានព្រះបន្ទូលថា:(وهذا كتاب أنزلناه مبارك فاتبعوه واتقوا لعلكم ترحمون)
មានន័យថា:យេីងបានបញ្ចុះគម្ពីរ(អាល់គូរអាន)នេះគឺដេីម្បីផ្តល់ពរជ័យចូរពួកអ្នកដេីរតាមចុះនៃគន្លងគូរអាននេះព្រមទាំងពួកឯងកោតខ្លាចទៅចំពោះអល់ឡោះ ធ្វេីដូច្នេះសង្ឃឹមថាពួកឯងទទួលបានការអាណិតអាសូរពីអល់ឡោះជាម្ចាស់។ ដូចអល់ឡោះបានមានបន្ទូលថា:

(ونزلنا عليك الكتاب تبيانا لكل شيء وهدى ورحمة وبشرى للمسلمين) الأنعام 100

មានន័យថា: យើងបញ្ចុះអោយឯង( មូហាំម៉ាត់)នូវគម្ពីរមួយសំរាប់បញ្ជាក់នូវអ្វីគ្រប់យ៉ាងទាំងអស់ និងដើម្បីផ្តល់នូវការចង្អុលបង្ហាញ និងសេចក្តីអាណិតអាសូរព្រមទាំងផ្តល់នូវដំណឹងសប្បាយរីករាយ ដល់អ្នកអ៊ីស្លាមទាំងឡាយ ។ មានកថាខណ្ឌជាច្រើន ដែលបានបញ្ជាក់ក្នុងរឿងទាំងនេះដែរ ។

## ៤-ជំនឿនឹងបណ្តារ៉ស៊ូលរបស់អល់ឡោះ

ចាំបាច់ត្រូវជឿនឹងរ៉ស៊ូលទាំងអស់ជាលក្ខណៈទូទៅ និងដោយពណ៌នាលំអិត យើងត្រូវជឿយ៉ាងពិតប្រាកដថាគេបានបញ្ជូនរ៉ស៊ូលមក ដើម្បីចង្អុលបង្ហាញប្រជាជនរបស់គេ នៅតាមជំនាន់នីមួយៗអំពីដំណឹងរីករាយចំពោះអ្នកមានជំនឿ និងរំលឹកព្រមានពួកកាហ្វៀរ ។ រ៉ស៊ូលទាំងនោះបានអំពាវនាវប្រជាជនរបស់គេទៅរកការពិត និងមានជំនឿទៅចំពោះអល់ឡោះ តែមួយគត់នរណាហើយទទួលយកនូវអ្វីដែលរ៉ស៊ូលបាននាំមក អ្នកនោះនឹងទទួលជ័យជំនះ និងជោគវាសនាល្អ តែចំពោះអ្នកដែលប្រឆាំងនឹងរ៉ស៊ូទាំងនោះពួកគេនឹងទទួលនូវវិប្បដិសារី និងក្តីខាតបង់ជាក់ជាមិនខាន ។ ចំណែកឯរ៉ស៊ូលចុងក្រោយនិងប្រសើរជាងគេក្នុងចំណោមរ៉ស៊ូលទាំងអស់នោះគឺណាពីយើងមូហាំម៉ាត់កូនរបស់អាប់ឌុលឡោះ ។អល់ឡោះបានមានព្រះបន្ទូលថា:

(ولقد بعثنا في كل أمة رسولا أن اعبدوا الله واجتنبوا الطاغوت)

មានន័យថា: ពិតប្រាកដយើងបានបង្កើតសំរាប់ប្រជាជនគ្រប់ជំនាន់នោះនូវ



រ៉ស៊ូល ដែលរ៉ស៊ូលទាំងនោះដឹកនាំពួកគេអោយគោរពប្រតិបត្តិទៅចំពោះអល់ឡោះតែមួយគត់និងចៀសវាងអោយឆ្ងាយអំពីការប្រតិបត្តិអ្វីមួយក្រៅពីអល់ឡោះ( ហៅថាស្ហៃតន) ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា:

(ما كان محمد أبا أحد من رجالكم ولكن رسول الله وخاتم النبيين)

មានន័យថា: ណាពីមូហាំម៉ាត់មិនមែនជាឪពុកនរណាម្នាក់ក្នុងចំណោមពួកឯង ប៉ុន្តែគេជារ៉ស៊ូលរបស់អល់ឡោះ និងជាណាពីចុងក្រោយគេបង្អស់ ។

❀ហើយចំពោះរ៉ស៊ូល ដែលអល់ឡោះបានបញ្ជាក់ឈ្មោះរបស់ពួកគេដូចជាណាពីនួស(نوح)ហ៊ូទ(هود)សឡេះ(صالح)អ៊ីបរ៉ហ៊ីម(إبراهيم) និងណាពីផ្សេងៗទៀតដែលអល់ឡោះមិនបានបញ្ជាក់ឈ្មោះគឺយើងត្រូវតែមានជំនឿទៅចំពោះពួកគេទាំងអស់ដោយគ្មានការមន្ទិលសង្ស័យអ្វីឡើយ ។

## ៥-ជំនឿនឹងថ្ងៃបរលោក

រីឯជំនឿនឹងថ្ងៃបរលោកគេរួមបញ្ចូលជាមួយដែរ នូវអ្វីដែលអល់ឡោះបានបញ្ជាក់ប្រាប់ប្រការទាំងនោះ ដូចជាជឿជាក់នូវអ្វីដែលកើតឡើងក្រោយពីស្លាប់រួចការធ្វើទណ្ឌកម្មនៅក្នុងផ្នូរនិងការទទួលលាភសក្ការៈ(نعمة)នៅក្នុងផ្នូរនិងជឿនូវអ្វីដែលកើតឡើងនៅថ្ងៃបរលោក ។ ដូចជាភាពតក់ស្លុតដ៏រន្ធត់នៅថ្ងៃនោះ និងជឿអំពីផ្លូវស្ពាន (صراط) ដែលមនុស្សត្រូវតែឆ្លងកាត់ទាំងអស់គ្នានៃមនុស្ស និងជឿជាក់ថាជញ្ជីងយុត្តិធម៌សំរាប់ថ្លឹងអំពើល្អ និងអំពើអាក្រក់របស់មនុស្សលោក ហើយជឿជាក់ថាមានការជំនុំជំរះក្តី (កាត់ក្តី)

នូវអំពើល្អ អំពើអាក្រក់របស់មនុស្ស និងការតបស្នង(جزاء)ចំពោះមនុស្ស នូវអ្វីដែលពួកគេបានសាងកន្លងមកកាលពីនៅក្នុងលោកីយ៏ ។ ហើយ ជឿជាក់ក្នុងថ្ងៃនោះដែរ ការចែកសៀវភៅ ឬបញ្ជី(លិខិត)ដល់មនុស្សទាំងអស់ ដោយអ្នកខ្លះទទួលលិខិតរបស់ខ្លួនដោយដៃខាងស្តាំ ហើយអ្នកខ្លះទទួលដោយដៃខាងឆ្វេង ឬទទួលយកពីក្រោយខ្នងរបស់ពួកគេ។ ហើយបញ្ចូលទៅក្នុងនេះដែរ ការជឿថាមានស្រះដែលគេផ្តល់អោយណាពីមូហាំម៉ាត់ និងជឿថាមានឋានសួគ៌ និងឋាននរក ហើយចាំបាច់ត្រូវជឿទៀតថា ការគន់មើលរបស់អ្នកមានជំនឿចំពោះម្ចាស់របស់គេ។ ប្រការផ្សេងៗទៀតដែលផ្តល់មកតាមរយៈអាល់គួរអាន និងហាហ្ទីសដ៏ត្រឹមត្រូវ គឺចាំបាច់លើយើងជឿជាក់ និងទទួលការពិត ទាំងអស់លើប្រការទាំងនោះតាមការចង្អុលបង្ហាញរបស់អល់ឡោះ និងរ៉សូ៊លរបស់ទ្រង់ ។

## ៦-ជំនឿលើការកំនត់វាសនាល្អឬអាក្រក់

ការជឿលើវាសនាល្អឬអាក្រក់គឺស្ថិតលើបួនចំនុចដូចខាងក្រោមៈ

**ចំនុចទី១:** ពិតប្រាកដអល់ឡោះដឹងនូវអ្វីដែលកើតមានរួចមកហើយ និងអ្វីដែលនឹងត្រូវកើតមានឡើងនៅពេលខាងមុខ ។អល់ឡោះមហាជ្រាបដឹងទាំងអស់នូវគ្រប់រឿងរ៉ាវសកម្មភាពរបស់មនុស្សលោក ហើយដឹងនូវការទទួលលាភសក្ការៈរបស់ពួកគេ ពេលវេលាបញ្ចប់នៃសង្ខាររបស់ពួកគេកិច្ចការសព្វសារពើរបស់ពួកគេ និងប្រការផ្សេងៗសុទ្ធតែនៅក្រោមការយល់ដឹងរបស់អល់ឡោះទាំងអស់ ដោយគ្មានការខ្វះចន្លោះពីការដឹងរបស់ទ្រង់ឡើយ ។

ដូចអល់ឡោះបានមានព្រះបន្ទូលថា:



(إن الله بكل شيء عليم) سورة الأنفال الآية : 75

មានន័យថា:ពិតប្រាកដណាស់អល់ឡោះដឹងនូវអ្វីៗទាំងអស់យ៉ាងល្អិតល្អន់ ។ អល់ឡោះបានមានព្រះបន្ទូលទៀតថា:

(لتعلموا أن الله على كل شيء قدير وأن الله قد أحاط بكل شيء علما) الطلاق :12

មានន័យថា: ដើម្បីពួកឯងដឹងអោយច្បាស់ពិតប្រាកដថាអល់ឡោះគឺមានសមត្ថភាពលើអ្វីៗទាំងអស់ ហើយពិតប្រាកដអល់ឡោះដឹងនូវអ្វីៗទាំងនោះដោយជ្រួតជ្រាបបំផុត ។

**ចំនុចទី២:** សំរាប់រាល់អ្វីៗទាំងអស់សុទ្ធតែចំណារ និងសំរេចនៅក្នុងកំនត់ត្រារបស់អល់ឡោះស៊ុបហាណាហ៊ូវ៉ាតើអាឡើទាំងអស់ ។បានសេចក្តីថារាល់វាសនាល្អអាក្រក់និងកិច្ចការសព្វសារពើរបស់សត្វលោកគឺសុទ្ធតែអល់ឡោះចារកំនត់រួចជាស្រេចមកហើយ ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា:

(وكل شيء أحصيناه في إمام مبين) سور يس الآية: 12

មានន័យថា: រាល់អ្វីទាំងឡាយសុទ្ធតែយើងបានកត់ត្រាលំអិត នៅក្នុងបញ្ជីកំនត់ត្រាដ៏ច្បាស់លាស់ ។ ហើយអល់ឡោះបានមានព្រះបន្ទូលទៀតថា:

(ألم تعلم أن الله يعلم ما في السماء والأرض إن ذلك في كتاب
إن ذلك على الله يسير) سورة الحج الآية : 70

មានន័យថា: តើឯងដឹងទេ! ច្បាស់ណាស់អល់ឡោះមហាជ្រាបដឹង នូវអ្វីៗ

គ្រប់យ៉ាងដែលមាននៅលើមេឃ និងនៅលើផែនដីយើងនេះសុទ្ធតែមាននៅក្នុងកំនត់ត្រារបស់អល់ឡោះរួចជាស្រេច តាមពិតងាយបំផុតសំរាប់អល់ឡោះ

នូវរឿងទាំងអស់។

**ចំនុចទី៣:** ត្រូវជឿថារាល់ហេតុការណ៍ដែលកើតឡើង ឬមិនទាន់បានកើតឡើង ទោះល្អក្តី ឬអាក្រក់ក្តីគឺសុទ្ធតែសំរេចទៅដោយចំនង់របស់អល់ឡោះ ប្រសិនបើអល់ឡោះមានបំណងរឿងនោះនឹងកើតឡើង ប៉ុន្តែបើអល់ឡោះមិនចង់ រឿងនោះមិនអាចកើតឡើងជាដាច់ខាត។ ដូចអល់ឡោះបានមានព្រះបន្ទូលថា: (إن الله يفعل ما يشاء) سورة الحج الآية : 18

មានន័យថា: ពិតប្រាកដអល់ឡោះធ្វើអ្វីមួយដែលទ្រង់ចង់។ អល់ឡោះមានបន្ទូលទៀតថា: (إنما أمره إذا أراد شيئا أن يقول له كن فيكون) មានន័យថា: តាមពិតកិច្ចការរបស់អល់ឡោះ នៅពេលដែលទ្រង់ចង់អោយអ្វីមួយកើតឡើង ទ្រង់គ្រាន់តែពោលថា ចូរកើតឡើង ប្រការនោះនឹងកើតឡើងមួយរំពេច។ អល់ឡោះបានមានបន្ទូលទៀតថា:

(وما تشاءون إلا أن يشاء الله رب العالمين) سورة التكوير الآية : 29

មានន័យថា: គ្រប់ហេតុការណ៍ទាំងអស់មិនមែនពួកឯងចង់នោះទេ ប៉ុន្តែអល់ឡោះជាម្ចាស់នៃពិភពទាំងឡាយវិញទេដែលមានបំណងដូច្នោះ។

**ចំនុចទី៤:** ត្រូវជឿថាធម្មជាតិដែលមានមកទាំងអស់សុទ្ធតែអល់ឡោះជាអ្នកបង្កើត។ ដោយគ្មានអ្នកផ្សេងណាមួយជាអ្នកបង្កើត ឬជាម្ចាស់ផ្សេងក្រៅពីអល់ឡោះឡើយ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា:

(الله خالق كل شيء وهو على كل شيء وكيل) سورة الزمر الآية : 62

មានន័យថា: អល់ឡោះជាអ្នកបង្កើតអ្វីៗទាំងអស់នោះ ហើយវាស្ថិតនៅ



ក្រោមការចាត់ចែង និងរ៉ាប់រងរបស់អល់ឡោះ។

※ជំនឿ និងការកំនត់ល្អ ឬអាក្រក់ គឺស្ថិតនៅលើបួនចំនុចនេះឯង ដែលមានចំពោះពួកអះលុស្ស៊ុណ្ណះ និងវ៉ាល់ជើម៉ាអះ ( أهل السنة والجماعة) តែមានការខ្វែងយោបល់គ្នាមួយចំនួនក្នុងរឿងនេះ ចំពោះពួកអះលីពិតអះ (អ្នកបង្កើតច្បាប់ថ្មីនៅក្នុងសាសនា)។

គេបូកបញ្ចូលចំពោះជំនឿនឹងអល់ឡោះ ដែលគេជឿជាក់ថាប្រាកដណាស់ជំនឿនោះអាចកើតថែមឡើងទ្វេដង ដោយបង្កើននូវការគោរព។ តែជំនឿក៏អាច ប្រណិប័តន៏ចំពោះអល់ឡោះទាំងពាក្យសំដី និងការអនុវត្តថយចុះដែរ ដោយសារការសាងអំពើបាបប៉ុន្តែមិនអាចចោទ ជនណាម្នាក់ថាជាកាហ្វេរ ដោយអំពើបាបរបស់គេនោះបានទេក្រៅពីអំពើស៊ីរិក និងអំពើដែលធ្វើអោយធ្លាក់ក្នុងកាហ្វេរ។ ដូចជាស៊ីណា(រួមរ័ក្សដោយមិនបានរៀបការ) លួចកេងប្រវ័ញ្ចទ្រព្យសម្បត្តិអ្នកដទៃ ផឹកគ្រឿងស្រវឹងអកតញ្ញូឪពុកម្តាយ និងប្រការផ្សេងៗទៀតដូចជាអំពើបាបកម្មធ្ងន់ៗ ដែលគេមិនអនុញ្ញាតអោយចោទគ្នាដូច្នោះឡើយ។ដូចអល់ឡោះបានមានព្រះបន្ទូលថា:

(إن الله لا يغفر أن يشرك به ويغفر ما دون ذلك لمن يشاء) سورة النساء الآية : 48

មានន័យថា: ពិតណាស់អល់ឡោះ មិនអាចលើកលែងទោសកំហុសបានទេចំពោះអ្នកដែលសាងអំពើស៊ីរិកនឹងអល់ឡោះ តែអល់ឡោះអាចលើកលែងទោសអោយបានចំពោះអំពើបាបកម្មណាដែលក្រៅពីអំពើស៊ីរិក ត្រង់អ្នកដែលចង់លើកលែងទោសអោយប៉ុណ្ណោះ។ ហើយមានហាហ្ទីសជាច្រើនបាន

និយាយ អះអាងដូចៗគ្នាអំពីរ៉សូ៊លុលឡោះដែលថា: តាមពិតអល់ឡោះ ដោះលែងពី នរកបានចំពោះអ្នកណាដែលក្នុងចិត្តរបស់គេ មានសារជាតិជំនឿសូម្បីតែមានទំងន់តូចប៉ុនធូលីក៏ដោយ ។

❀អំពីជំនឿនឹងអល់ឡោះទៀត គឺត្រូវស្រឡាញ់នូវអ្វីដែលអល់ឡោះស្រឡាញ់ ឬយល់ព្រម និងចេះស្អប់នូវអ្វីដែលអល់ឡោះស្អប់បានសេចក្តីថាស្រឡាញ់ក៏ក្នុងសាសនាអល់ឡោះ ស្អប់ក៏ក្នុងសាសនាអល់ឡោះចេះស្រឡាញ់គាំទ្រក៏នៅក្នុងសាសនាអល់ឡោះ ហើយចាត់ទុកជាសត្រូវ ក៏នៅក្នុងនាមសាសនាអល់ឡោះ ។ ដូច្នេះចាំបាច់លើអ្នកមានជំនឿ និងអ្នកមានជំនឿដូចគ្នាត្រូវអោយគេចេះស្រឡាញ់ និងគាំទ្រគ្នាទៅវិញទៅមក ហើយមិនត្រូវពេញចិត្ត ឬគាំទ្រចំពោះកាហ្វៀរហើយត្រូវចាត់ទុកពួកគេថាជាសត្រូវនឹងអ្នកមានអ៊ីម៉ាន ។

-ចំពោះអ្នកមានជំនឿកំពូលគឺជាគូកនរបស់ណាពីមូហាំម៉ាត់ ។

-ចំពោះពួកអះលីស៊ុណ្ណះវ៉ាល់ជើម៉ាអះ គឺពួកគេមានការស្រឡាញ់គាំទ្រ និងជឿជាក់ថាពិតប្រាកដគូកនរបស់ណាពី ដែលប្រសើរបំផុតបន្ទាប់ពីពួកណាពី ពីព្រោះណាពីមូហាំម៉ាត់បានមានប្រសាសន៍ថា:

(خير القرون قرني ثم الذين يلونهم ثم الذين يلونهم) متفق عليه

មានន័យថា: សតវត្សដែលល្អប្រសើរបំផុតនោះ គឺនៅក្នុងសតវត្សយើងនេះឯង បន្ទាប់មកពួកអ្នកដែលស្ថិតនៅសតវត្សបន្ទាប់ពីណាពីក្រោយមកពួកអ្នកដែលនៅសតវត្សទីបីបានសេចក្តីថា ជំនាន់មនុស្សដែលកាន់ត្រឹមត្រូវល្អប្រសើរបរិសុទ្ធបំផុតនោះ គឺស្ថិតនៅក្នុងកំឡុងបីសតវត្សនេះឯង ។ ហើយ



ពួកគេជឿជាក់ថា ពិតប្រាកដអ្នកប្រសើរបំផុតក្នុងចំនោមពួកគេនោះ គឺអាពូពើកើរ( អាស្ស៊ិតហ្ញីក) បន្ទាប់មកអ៊ូម៉ើរអាល់ហ្វារូក ឧស្មានហ្ប៊ុលនូរ៉ៃននឹងអាលី ។ បន្ទាប់ពីនោះគឺពួកទាំង១០នាក់ដែលធានាចូលឋានសួគ៌ និងគូកនទាំងអស់របស់ណាពីមូហាំម៉ាត់ ។ ហើយពួកអះលុស្ស៊ុណ្ណះ វ៉ាល់ជើម៉ាអះនោះទៀតពួកគេប្រកាន់រក្សានូវភាពស្ងៀមស្ងាត់ នូវអ្វីដែលបានកើតឡើងនូវទំនាស់ដែលស្វែងយល់ និងទទួលនូវភាពត្រឹមត្រូវសំរាប់គេនោះទទួលបានផលបុណ្យពីរ ហើយចំពោះអ្នកដែលទទួលរងនូវការ ខុសឆ្គងក្នុងរឿងស្វែងរកនោះត្រូវទទួលបានផលបុណ្យ១ពួកគេទាំងអស់គោរពស្រឡាញ់ចំពោះក្រុមគ្រួសារណាពីដែលមានការជឿជាក់លើណាពី ហើយមានការស្រឡាញ់គាំទ្រទាំងអស់ពិសេសភរិយាណាពីដែលជាមាតានៃអ្នកមានជំនឿ ។

❀ពួកអះលីស៊ុណ្ណះវ៉ាល់ជើម៉ាអះនោះដែរ ពួកគេរួចចាកផុតពីរបៀបដូចពួករ៉ហ្វិដោះ (ជាពួកដែលខឹងសម្បា ចំពោះគូកនរបស់រ៉សូ៊លុលឡោះ) ហើយពួកគេដាក់បណ្តាសារចំពោះគូកនរបស់ណាពី ព្រមទាំងអោយតំលៃនិងលើកតំកើងក្រុមគ្រួសាររបស់អាលី អោយខ្ពស់ហួសពីឋានៈរបស់គូកនរបស់ណាពីដទៃទៀត ។ ដូច្នេះដែរពួកអះលីស៊ុណ្ណះវ៉ាល់ជើម៉ាអះ រួចចាកផុតពីពួកខវ៉ារិច (خوارج) ជាពួកដែលស្អប់ ខ្ពើមក្រុមគ្រួសាររបស់អាលី ។ អ្វីៗដែលយើងបានរំលឹកមកនេះវាស្ថិតនៅក្នុងទ្រឹស្តីដ៏សង្ខេបនៃគោលជំនឿដ៏ត្រឹមត្រូវដែលអល់ឡោះបញ្ចុះរ៉សូ៊លរបស់ទ្រង់ មូហាំម៉ាត់គឺស្ថិតនៅលើគោលជំនឿនេះឯង ។ ហើយអះលុស្ស៊ុណ្ណះវ៉ាល់ជើម៉ាអះ ប្រកាន់យកគោលជំនឿដ៏ត្រឹមត្រូវនេះ ។ ដូចរ៉សូ៊លុលឡោះបានមានប្រសាសន៍ថា:

قال عليه الصلاة والسلام :(لا يزال طائفة من أمتي على الحق منصورة لا يضرهم من خذلهم حتى يأتي أمر الله سبحانه)

មានន័យថាៈមួយក្រុមអំពីប្រជាជនយើងនោះមិនអាចសាបសូន្យ គឺពួកគេស្ថិតនៅលើការពិតជានិច្ច ដោយគ្មានឧបសគ្គណាមករារាំងបោកបញ្ឆោតចំពោះពួកគេបានទេ រហូតដល់ការសំរេចរបស់អល់ឡោះ។ ដូចរ៉ស៊ូលុលបានមានប្រសាសន៍ទៀតថាៈ

قال عليه الصلاة والسلام ( افترقت اليهود على إحدى وسبعين فرقة، وافترقت النصارى على اثنتين وسبعين فرقة، وستفترق هذه الأمة على ثلاث وسبعين فرقة ، كلها في النار إلا واحدة فقال الصحابة: من هي يا رسول الله ؟ قال : من كان على مثل ما أناعليه وأصحابي ).

បានសេចក្តីថាៈណាពីបានបញ្ជាក់ប្រាប់យើងថា ពួកយ៉ាហ៊ូឌី ពួកគេបែកទៅ

ជា៧១ ក្រុម ។ ហើយពួកណាសរ៉នីបែកជា៧២ក្រុម ហើយគាត់បានបញ្ជាក់យ៉ាងច្បាស់ថា រីឯចំពោះប្រជាជនរបស់ខ្ញុំនឹងបែកទៅជា៧៣ក្រុមដែលពួកគេសុទ្ធតែចូលនរកទាំងអស់លើកលែងតែមួយក្រុមប៉ុណ្ណោះ ដែលចូលឋានសួគ៌។ នៅខណៈនោះមានគូកនរបស់ណាពីសួរទៅកាន់ណាពីថាៈតើនរណាដែលជាក្រុមចូលសួគ៌ានោះ? ណាពីបានឆ្លើយថា គឺពួកដែលប្រកាន់ខ្ជាប់ដូចយើង និងដូចពួកគូកនរបស់យើងនោះឯង។ នេះហើយជាគោលជំនឿដែលត្រូវប្រកាន់យក និងឈរលើជំនឿនេះដោយប្រុងប្រយ័ត្នអំពីអ្វីដែលធ្វើអោយប្រាសចាកចេញពីគោលជំនឿដ៏ត្រឹមត្រូវនោះ។

- ចំពោះពួកដែលកែប្រែនិងដើរប្រាសចាកផ្ទុយពីគោលជំនឿដ៏ត្រឹមត្រូវនោះ



គឺមានច្រើនក្រុមដូចមានបញ្ជាក់នៅខាងក្រោមៈ

- មួយចំនួនអំពីពួកគេនោះគឺជាអ្នកដែលគោរពបូជាចំពោះរូបចំលាក់រូបបដិមា ចំពោះម៉ាឡាអ៊ីកាត់ វ៉ាលី ជិន(បីសាច)ដើមឈើ ដុំថ្ម និងវត្ថុផ្សេងៗទៀត។

ពួកគេទាំងនេះពុំបានទទួលនូវការអំពាវនាវពីរ៉ស៊ូលតែថែមទាំងប្រព្រឹត្តិខ្វែងពីបណ្តាំរ៉ស៊ូល ដូចអ្វីដែលបានប្រព្រឹត្តិកន្លងមក ហើយពួកគូរ៉ៃស៏ និងក្រុមពួកអារ៉ាប់បានគោរពខ្វែងគ្នានឹងណាពីយើងមូហាំម៉ាត់ ហើយពួកគេតែងតែបួងសួងសុំពីវត្ថុ ឬអ្វីដែលពួកគេគោរពបូជាដើម្បីសំរេចនូវបំនង របស់ពួកគេ។ ដូចជាសុំអោយជាសះស្បើយពីជំងឺរបស់ពួកគេ ឬសុំអោយទទួលជ័យជំនះលើសត្រូវទាំងឡាយ។ ហើយពួកគេសំឡេះសត្វដើម្បីបូជាថ្វាយចំពោះវត្ថុ ទាំងនោះឬរំលឹកដឹងគុណចំពោះម្ចាស់ទាំងនោះ។ នៅពេលដែលរ៉ស៊ូលុលឡោះ ធ្វើការបដិសេធប្រឆាំងនូវអំពើរបស់ពួកគេទាំងនោះ ហើយប្រើអោយពួកគេ មានការជ្រះថ្លាក្នុងការគោរពប្រតិបត្តិចំពោះ អល់ឡោះតែមួយគត់ បែរជាពួកគេមានការចំឡែកក្នុងរឿងដូច្នេះ ហើយប្រកែកប្រឆាំងចំពោះ រ៉ស៊ូលុលឡោះទៅវិញដោយពួកគេពោលថាៈ

(أجعل الآلهة إلها واحدة إن هذا لشيء عجاب)

មានន័យថាៈ តើការបង្កើតម្ចាស់ទាំងអស់នោះ ធ្វើជាម្ចាស់តែមួយរឺ? ពិតប្រាកដនេះ ជាប្រការដែលគួរអោយចំឡែកមែន?។ រ៉ស៊ូលុលឡោះ ពុំបានបញ្ឈប់នូវការអំពាវនាវពួកគេទៅរកអល់ឡោះឡើយ ហើយធ្វើការព្រមានបញ្ឈប់ អំពីប្រការស៊ីរិក និងព្យាយាមពន្យល់បញ្ជាក់ចំពោះពួកគេនូវធាតុ

ពិតដែលរ៉ស៊ូលុលឡោះអំពាវនាវទៅរកនោះ រហូតពួកគេទទួលបានការចង្អុលបង្ហាញផ្លូវត្រូវពីអល់ឡោះ។ ក្រោយពីពួកគេទទួលការចង្អុលបង្ហាញពីអល់ឡោះ រួចពួកគេក៏នាំគ្នាចូលក្នុងសាសនាអល់ឡោះទាំងក្រុមៗ។ ក្រោយមកសាសនាអល់ឡោះ ក៏បានលេចធ្លោលើសាសនាដទៃទៀតបន្ទាប់ពីការអំពាវនាវចេះតែបន្ត និងការតស៊ូដ៏យូរអង្វែងរបស់រ៉ស៊ូលុលឡោះ រួមជាមួយគូកនរបស់ លោកព្រមទាំងអ្នកបន្ទាប់ពីគូកន តែក្រោយមករឿងរ៉ាវទាំងនោះក៏បានប្រែប្រួល ហើយកើតឡើងនូវភាពល្ងង់ខ្លៅមានប្រៀបលើមនុស្សទាំងឡាយ រហូតដល់ពួកគេភាគច្រើន វិលត្រឡប់ទៅរកសាសនាមុនណាពីមូហាំម៉ាត់ ដោយពួកនិយមជ្រុលក្នុងការជឿចំពោះបណ្តាណាពី និងវ៉ាលី ហើយពួកគេបែរជាបួងសួង និងសុំជំនួយពីពួកណាពី និងវ៉ាលី និងអ្នកផ្សេងៗទៀត ដែលជាប្រការស៊ីរិកនឹងអល់ឡោះទៅវិញ។ មានច្រើនប្រភេទនៃអំពើស៊ីរិករបស់ ពួកគេដោយពួកគេពុំបានយល់អំពីខ្លឹមសារ (لا إله إلا الله) ដូចអ្វីដែលបានដឹងរួចមកហើយរបស់ពួកកាហ្វៀរអារ៉ាប់ តែពួកគេនៅតែស៊ីរិក។ ស៊ីរិកទាំងនេះមិនសាបសូន្យ ទេតែថែមទាំងរីកសុសសាយរហូតដល់មនុស្សជំនាន់យើងទៀត។ នេះដោយសារតែភាពល្ងង់ខ្លៅបានគ្របដណ្តប់លើ មនុស្សនាជំនាន់ក្រោយពីណាពី។ ការអៀកទីកត់ស៊ុបហ៊ាះ(ជំនឿច្រឡូកច្របល់មិនច្បាស់លាស់)យកប្រការប៉ាតាល់ ធ្វើជាការពិតនៃអ្នកជំនាន់ក្រោយគឺវាស្មើនឹងស៊ុបហ៊ាះនៃអ្នកជំនាន់មុនដូច្នេះឯងវាគ្រាន់តែអ្នកជំនាន់មុនយកវត្ថុឥតវិញ្ញាណជាជាស្ពានឬជាលែសនៃការធ្វើអ៊ីប៉ាដាត់ចំពោះអល់ឡោះរីឯអ្នកជំនាន់ក្រោយយកណាពីឬវ៉ាលីធ្វើអ៊ីប៉ាដាត់ជាលែសទៅលើ អល់ឡោះប៉ុណ្ណោះ។ ដូចពាក្យសំដីរបស់ពួកគេថា



(هؤلاء شفعاؤنا عند الله)

មានន័យថាៈ ពួកទាំងនេះ(ម្ចាស់ដែលពួកគេស៊ីរិកនឹងអល់ឡោះ)អាចជួយរុញបញ្ជិតពួកយើងទៅនឹងអល់ឡោះ។ ដូចអល់ឡោះមានព្រះបន្ទូលថាៈ

(ما نعبدهم إلا ليقربونا إلى الله زلفى) سورة الزمر الآية: 3

មានន័យថាៈ យើងមិនបានសំពះធ្វើការប្រតិបត្តិទៅចំពោះអ្នកទាំងនោះទេ វាគ្រាន់តែដើម្បីពួកទាំងនោះបញ្ជិតខ្លួនពួកយើងទៅចំពោះអល់ឡោះអោយកាន់តែជិតតែប៉ុណ្ណោះ។ ពិតប្រាកដណាស់អល់ឡោះបានបដិសេធពួកទាំងនេះថែមទាំងបញ្ជាក់ថា នរណាហើយគោរពប្រណិបត្តិចំពោះវត្ថុ ឬគោរពអ្វីមួយក៏ដោយក្រៅពីអល់ឡោះនោះ ពិតប្រាកដអ្នកទាំងនោះកំពុងធ្វើអំពើស៊ីរិកនឹងកាហ្វៀរ(ប្រឆាំង)ចំពោះអល់ឡោះយ៉ាងជាក់ស្តែង ។ដូចអល់ឡោះបានមានព្រះបន្ទូលថាៈ

(ويعبدون من دون الله مالا يضرهم ولا ينفعهم ويقولون هؤلاء شفعاؤنا عند الله) سورة يوسف الآية: 11

មានន័យថាៈ ពួកគេគោរពប្រណិបត្តិផ្សេងពីអល់ឡោះនូវអ្វីដែលមិនអាចផ្តល់ឧបសគ្គ និងមិនអាចផ្តល់ផលប្រយោជន៏ចំពោះពួកគេអ្វីបន្តិចសោះឡើយ។ ហើយពួកគេពោលថាៈអ្វីទាំងអស់នេះអាចសុំជំនួយពីអល់ឡោះជួយដល់ពួកយើងទាំងអស់គ្នាបាន ពិតណាស់អល់ឡោះបានបញ្ជាក់នៅក្នុងអាយ៉ាត់ជាច្រើនដែលថា ការគោរពបូជាអ្វីផ្សេងក្រៅពីអល់ឡោះ ដូចជាគោរពបូជាទៅចំពោះណាពីវ៉ាលី ឬផ្សេងពីពួកគេ គឺជាអំពើស៊ីរិកដ៏ធំធេង

ទោះជាពួកគេអោយឈ្មោះផ្សេងក្រៅពីនេះក្តី។ អល់ឡោះបានបញ្ជាក់ដែរថា:(والذين اتخذوا من دونه أولياء ما نعبدهم إلا ليقربونا إلى الله زلفى) ចំពោះពួកដែលទទួលយកអ្វីផ្សេង ក្រៅពីអល់ឡោះធ្វើជាមេដឹកនាំ ហើយពួកគេដោះសារថា យើងមិនបានគោរពបូជាពួកទាំងនោះទេប៉ុន្តែ យើងធ្វើនេះដើម្បីពួកគេជួយបញ្ជិតយើងទៅចំពោះអល់ឡោះ ក្នុងកិច្ចការគោរពបូជារបស់យើង។ ហើយអល់ឡោះបានច្រានចោលនូវអំពើរបស់ពួក គេទាំងនេះដោយពោលបញ្ជាក់ថា:

(إن الله يحكم بينهم فيما هم فيه يختلفون إن الله لا يهدي من هو كاذب كفار) سورة الزمر الآية: 3

មានន័យថា: ពិតប្រាកដណាស់អល់ឡោះនឹងកាត់ក្តីរវាងពួកគេនូវអ្វីដែលខ្វែងគំនិតគ្នា ហើយអល់ឡោះក៏មិនចង្អុលបង្ហាញផ្លូវត្រូវចំពោះអ្នកដែលភូតកុហកពីការពិត និងប្រឆាំងអល់ឡោះនោះដែរ។ ដូច្នេះរាល់ការគោរពបូជាអ្វីមួយផ្សេងពីអល់ឡោះគិតទាំងការបួងសួង សុំការកោតខ្លាច ការប៉ងប្រាថ្នាពីអ្វីមួយផ្សេងពីអល់ឡោះ សុទ្ធតែជាអំពើស៊ីរិកនឹងអល់ឡោះ។ ហើយពួកគេកុហកបោកប្រាស់ថាម្ចាស់ដែលពួកគេគោរពបូជាទាំងនោះអាចផ្តល់ភាពជិតស្និតក្នុងការគោរពបូជាទៅចំពោះអល់ឡោះ។

❀អំពីជំនឿដែលប្រឆាំងនិងផ្ទុយពីគោលជំនឿដ៏ត្រឹមត្រូវ និងប្រព្រឹត្តិខុសពីអ្វីដែលបណ្តារ៉ស៊ូលនាំមកនោះគេជឿថាគ្មានសាសនា ឬគ្មានជំនឿអ្វីទាំងអស់ពិសេសនៅសម័យនេះគេកាន់តាមលទ្ធិម៉ាកលេនីន ឬក្រៅពីអ្នកទាំងពីរនេះទៀតដែលសុទ្ធតែបដិសេធប្រឆាំងនឹងសាសនា។ ពួកទាំងនេះគឺ



កាន់តាមលទ្ធិសង្គមនិយម ឬកុម្មុយនីសនិយម ឬលទ្ធិមិនចូលបក្សសម្ព័ន្ធនិងផ្សេងៗទៀតដែលគេប្រើឈ្មោះខុសៗគ្នា។គោលការណ៍របស់ពួកគេនោះគឺមិនព្រមទទួលថាមានម្ចាស់បង្កើតអ្វីឡើយ ហើយការរស់រានមានជីវិតគឺម្ចាស់ការដោយខ្លួនឯង។អំពីមូលដ្ឋាននៃគោលការណ៍របស់ពួកគេនោះទៀតគឺប្រកែកយ៉ាងដាច់អហង្ការមិនជឿថាមានការវិលត្រឡប់ទៅរកអល់ឡោះមិនជឿថាមានឋានសួគ៌ ឋាននរកមិនតែប៉ុណ្ណោះពួកគេថែម ទាំងបដិសេធទាំងអស់សាសនាដែលមាននៅលើពិភពលោកនេះ។ប្រសិនបើនរណាហើយបានឃើញ និងសិក្សាសៀវភៅរបស់ពួកគេ ពិតប្រាកដអ្នកនោះនឹងជ្រាបច្បាស់ ហើយក៏គ្មានការសង្ស័យអ្វីឡើយដែលថាគោលជំនឿរបស់ពួកគេ គឺផ្ទុយទាំងស្រុងពីសាសនាដែលអល់ឡោះបញ្ចុះពីមេឃមកអោយមនុស្ស រហូតដល់ទីបញ្ចប់ជំរុញអោយពួកនោះធ្លាក់ក្នុងជ្រោះដ៏សែនអាក្រក់ទាំងលោកីយ៍និងបរលោក។

❀គោលជំនឿដែលផ្ទុយពីការពិត គឺអ្វីដែលបានជឿជាក់របស់ពួកគេរបៀបខាងក្នុង និងខ្លះទៀតតាមរបៀបស៊ូហ្វីយ៉ះ (صوفية) ហើយពួកខ្លះទៀតលើកតំកើងវ៉ាលីដោយជឿថាវ៉ាលីទាំងនោះជាអ្នកចូលរួមចំណែកនឹងអល់ឡោះ ក្នុងការចាត់ចែងតាមដាននូវកិច្ចការក្នុងពិភពលោក និងចាត់ទុកអ្នកទាំងនេះជាអ្នកទ្រទ្រង់ចក្រវាឡឬជាអ្នកថែរក្សានៃភពផែនដីហើយពួកគេយល់ថាពិភពលោកីយ៍បើគ្មានអ្នកទាំងនេះនឹងសាបសូន្យដល់ទីបញ្ចប់ឈ្មោះនៃពួកវ៉ាលីទាំងនេះមានដូចជាៈ (الأقطـاب والأوتـاد والأغـواث) និងមានឈ្មោះផ្សេងៗទៀតដែលសុទ្ធតែពួកគេគេចាត់ទុកថា ជាម្ចាស់ចាត់

ថែងសំរាប់ពួកគេ។ ក្នុងចំណុចនេះពិតជាអាក្រក់ណាស់នៃ ស៊ីរិក (الربوبية) ដែលយកមនុស្សរួមចំនែកចាត់ចែងជាមួយអល់ឡោះ ហើយស៊ីរិកខុសបែបនេះសឹងថាអាក្រក់ជាងពួកអារ៉ាប់កាលពីសម័យមុនណាពីមូហាំម៉ាត់ទៅទៀត ដោយកាហ្វេរសម័យមុនគេមិនបានស៊ីរិក (الربوبية) នេះទេតាមពិតពួកគេគ្រាន់តែស៊ីរិកក្នុងការ គោរពបូជាប៉ុណ្ណោះបានន័យថា ពួកគេគ្រាន់តែគោរពបូជាម្ចាស់ផ្សេងរួមជាមួយអល់ឡោះប៉ុណ្ណោះហើយស៊ីរិកពួកគេនៅពេលដែលពួកគេមិនបានជួបប្រទះនូវឧបសគ្គប៉ុណ្ណោះ តែនៅពេលណាមួយពួកគេជួបប្រទះឧបសគ្គនូវគ្រោះថ្នាក់កើតឡើងពួកគេបែរទៅរកអល់ឡោះ ដោយជ្រះថ្លាក្នុងការបួងសួងសុំពីអល់ឡោះដើម្បីរួចចាកផុតពីគ្រោះអាសន្ននោះ។ ដូចអល់ឡោះ មានព្រះបន្ទូលថា:

(فإذا ركبوا في الفلك دعوا الله مخلصين له الدين فلما نجاهم إلى البر إذا هم يشركون) سورة العنكبوت الآية : 65

មានន័យថា: នៅពេលណាពួកគេស្ថិតនៅលើសំពៅកណ្តាលសមុទ្រហើយគេខ្លាចមានគ្រោះថ្នាក់នូវហេតុការណ៍អ្វីមួយ ពួកគេបួងសួងសុំពីអល់ឡោះ ដោយជ្រះថ្លាក្នុងសាសនាអល់ឡោះប៉ុន្តែនៅពេលដែលអល់ឡោះអោយពួកគេរួចចាកផុតបានទៅដល់គោលដៅ ពេលនោះពួកគេបែរទៅជាធ្វើអំពើស៊ីរិកនឹងអល់ឡោះដដែល។ រីឯចំពោះការជឿថាអល់ឡោះជាអ្នកបង្កើតធម្មជាតិនិងគ្រប់គ្រងនូវប្រភពធម្មជាតិទាំងនោះគឺក្រោមដៃរបស់អល់ឡោះតែមួយគត់ ពួកនេះទទួលស្គាល់យ៉ាងជាក់ច្បាស់។ ដូចអល់ឡោះមានព្រះបន្ទូលថា:(**ولئن سألتهم من خلقهم ليقولن الله**) មានន័យថា:នៃមូហាំម៉ាត់



ប្រសិនបើឯងសួរពួកគេថា តើនរណាជាអ្នកបង្កើតពួកគេទាំងអស់គ្នា ពិតប្រាកដពួកគេនឹងឆ្លើយថាអល់ឡោះ។ អល់ឡោះបានមានបន្ទូលទៀតថា:

(قل من يرزقكم من السماء والأرض أم من يملك السمع والأبصار ومن يخرج الحي من الميت ويخرج الميت من الحي ومن يدبر الأمر فسيقولون الله فقل أفلا تتقون) سورة يونس الآية : 31

មានន័យថា:ឱមូហាំម៉ាត់ ! ចូរអ្នកពោលទៅកាន់ពួកគេថាតើនរណាជាអ្នក

ផ្តល់លាភសក្ការ:(រីស្គី)ដល់ពួកឯងអំពីមេឃ និងដី ឬនរណាជាអ្នកគ្រប់គ្រងការលឺ ឃើញ និងនរណាជាអ្នកពង្រស់ជីវិតអ្នកដែលបានស្លាប់ទៅ ហើយសួរពួកគេទៀតថា នរណាជាអ្នកចាត់ចែងនូវគ្រប់កិច្ចការរបស់សត្វលោក។ ពិតប្រាកដពួកគេនឹងឆ្លើយថា:អល់ឡោះចុះហេតុអ្វីបានជាពួកឯងគ្មានការគោរពកោតខ្លាចទៅចំពោះអល់ឡោះ? ។

❀ពួកអ្នកដែលសាងអំពើស៊ីរិកជំនាន់ក្រោយលើសពីពួកស៊ីរិកមុនៗត្រង់២ចំនុច:

១-ពួកគេខ្លះស៊ីរិករូពូពីយ៉ះ (យកវត្ថុផ្សេងធ្វើជាម្ចាស់រួមនឹងអល់ឡោះ)ក្នុងការគ្រប់គ្រងចាត់ចែងអ្វីៗគ្រប់យ៉ាងទាំងអស់។

២-ពួកគេស៊ីរិកទាំងពេលជួបប្រទះគ្រោះអាសន្ន ឬទាំងពេលគ្មានអាសន្ន ដូចអ្វីដែលគេបានដឹង ឃើញពីរឿងរ៉ាវរបស់ពួកនេះ ដូចជាពួកគេបានប្រព្រឹត្តចំពោះផ្នូរអាល់ហ៊ូសេននិងអាល់ពើតាវី ឬក្រៅពីអ្នកទាំងពីរនេះដែលស្ថិតនៅប្រទេសអេហ្ស៊ីប ហើយគេឃើញពួកគេប្រព្រឹត្តិអំពើស៊ីរិកដូច្នោះដែរនៅត្រង់ផ្នូររបស់អាល់អ៊ីតរូស (العيدروس) នៅអាឌាន (عدن)

តំបន់មួយនៃប្រទេសអារាប់យ៉េមែន ផ្នូររបស់អាល់ហ៊ើឌី (الهادي)នៅប្រទេសយ៉េមែន កូនរបស់អារាប៊ី ( ابن عربي ) នៅស្ហាម( នៅស៊ីរី) សៀខអាប់ឌុលកទៀរអាល់ជៃឡានី(عبد القادر الجيلاني)នៅអ៊ីរ៉ាក់ និងទីផ្នូរជាច្រើនទៀតដែលគេយកធ្វើកន្លែងគោរពបូជាក្រៅពីអល់ឡោះ។ ហើយមានអ្នកភាគតិចណាស់ដែលជំទាស់ និងបញ្ជាក់ប្រាប់ពួកគេអំពីធាតុពិតគោលជំនឿដែលអល់ឡោះ បង្កើតណាពីមូហាំម៉ាត់ និងរ៉ស៊ូលមុនៗមក។ តាមពិតអ្វីៗសំរេចទៅដោយអល់ឡោះ ហើយគង់តែត្រឡប់ទៅរកអល់ឡោះទាំងអស់គ្នា។យើងសុំពីអល់ឡោះអោយបង្កើនអ្នកអំពាវនាវទៅរកផ្លូវត្រឹមត្រូវដែលអល់ឡោះចង្អុលបង្ហាញ និងសុំអោយអល់ឡោះសំរេច ចំពោះអ្នកដឹកនាំអ៊ីស្លាមព្រមទាំងសាសនវិទូទាំងអស់ ដើម្បីប្រឆាំងនឹងអំពើស៊ីរិកទាំងនេះយ៉ាងដាច់ខាត។

❀អំពីគោលជំនឿ ដែលផ្ទុយពីគោលជំនឿដែលត្រឹមត្រូវនោះទៀតគឺនៅក្នុងបញ្ហាអាល់អិស្មាក និងស៊ីហ្វាត (លក្ខណៈសម្បត្តិ) ពួកគេជឿនូវគោលជំនឿរបៀបនេះ គឺពួកអះលីពិតអះ នៃពួកជុសមីយ៉ះ មូកតើស៊ីឡះ។ និងអ្នកដែលដើរតាមពួកគេទាំងនោះដោយពួកគេបដិសេធស៊ីហ្វាតអល់ឡោះ និងតាក់ទីលនូវស៊ីហ្វាតអល់ឡោះ ដែលគ្រប់លក្ខណៈ ម្តងពួកគេប្រដូចស៊ីហ្វាតអល់ឡោះទៅនឹងស៊ីហ្វាតអ្វីដែលគ្មានទាល់តែសោះម្តងពួកគេប្រដូចស៊ីហ្វាតអល់ឡោះទៅនឹងស៊ីហ្វាតអ្វីដែលគ្មានវិញ្ញាណ និងមិនទទួលស្គាល់ថាអល់ឡោះមានស៊ីហ្វាត ដូច្នេះនោះឡើយ តែធាតុពិតរបស់អល់ឡោះ នោះជ្រះស្អាតអំពីពាក្យសំដីដែលចោទប្រកាន់របស់ពួកគេ។ ហើយគេចាត់ទុកថា



ដូចគ្នានេះដែរ ចំពោះអ្នកដែលបដិសេធស៊ីហ្វាតមួយចំនួននៃស៊ីហ្វាត របស់អល់ឡោះនិងរក្សាទុកមួយចំនួនគេចាំបាច់រក្សាទុកអំពីស៊ីហ្វាតណាដែលសមស្របទៅនឹងការយល់ឃើញរបស់ពួកគេ ហើយពួកគេបដិសេធនូវស៊ីហ្វាតមួយចំនួន ដោយពួកទាំងនេះបកស្រាយបង្វែងន័យខ្លឹមសារ ដែលបង្ហាញពីភស្តុតាងពិតបញ្ជាក់ពីស៊ីហ្វាតទាំងនោះពួកគេធ្វើអោយប្រាស់ចាកខុសពីការពិតទាំងការស្តាប់និងស្វែងយល់នូវភស្តុតាងអំពីគួរអាននិងស៊ុណ្ណះ។

រីឯអះលីស៊ុណ្ណះវ៉ាល់ជើម៉ាអះវិញគឺពួកគេរក្សាទុកសំរាប់អល់ឡោះដូចអ្វីដែលបានបញ្ជាក់ជូនដោយខ្លួនទ្រង់ផ្ទាល់ ឬដូចអ្វីដែលរ៉ស៊ូលុលឡោះបានអះអាងច្បាស់អំពីអិស្មាក និងស៊ីហ្វាតតាមរបៀបគ្រប់លក្ខណៈ ហើយពួកគេជ្រះស្អាតអំពីការប្រៀបប្រដូចអល់ឡោះ ទៅនឹងអ្វីដែលអល់ឡោះបង្កើតមកដូច្នោះពួកគេប្រព្រឹត្តអ្វីៗទាំងអស់ គឺទៅតាមភស្តុតាងដែលអល់ឡោះ និងរ៉ស៊ូលុលឡោះបានផ្តល់មកដោយគ្មានការកែប្រែ ឬប្រដូចអ្វីទាំងអស់។ ហេតុដូចនេះពួកគេអាចរួចចាកផុតពីអ្វីដែលធ្លាក់ទៅលើពួកដែលនិយាយរួចដូចបានរៀបរាប់ខាងលើ។

នេះគឺជាផ្លូវដែលត្រឹមត្រូវនិងទទួលជោគជ័យទាំងលោកយើងនេះ និងទាំងបរលោក។ ហើយមាគ៌ាដ៏ត្រឹមត្រូវនេះដែរគឺ ជាគន្លងនៃអ្នកជំនាន់មុនទាំងបណ្តាអ៊ីម៉ាំ និងប្រជាជនជំនាន់នេះ។ ពួកគេមិនបានកែសំរួលអ្វីទាំងអស់ក្រៅពីអ្វីដែលបានកែសំរួលដោយក្រុមសាសនវិទូមុនៗ ដែលគេប្រតិបត្តិតាមគួរអាន និងស៊ុណ្ណះទាំងអស់នឹងបោះបង់ ចោលអ្វីដែលមិនឯកភាពតាមអាល់គួរអាន និងស៊ុណ្ណះ។

# ប្រការៗដែលអន្តរាយដល់អ៊ីស្លាម

# نواقض الإسلام

បងប្អូនអ៊ីស្លាមទាំងឡាយ! ចូរអ្នកជ្រាបចុះថា:ពិតប្រាកដអល់ឡោះហ្ស៊ូស៊ុបហាណាហ៊ូវ៉ាតាអាឡើ ដាក់កាតព្វកិច្ចលើមនុស្សទាំងឡាយដែលជាខ្ញុំរបស់អល់ឡោះ អោយពួកគេចូលក្នុងសាសនាអ៊ីស្លាម ហើយអោយពួកគេកាន់អោយបានខ្ជាប់ខ្ជួននឹងអ៊ីស្លាមនេះហើយត្រូវជៀសវាងអំពីអ្វីដែលធ្វើអោយប្រាសចាកខុសពីអ៊ីស្លាមនោះ។ ការដែលអល់ឡោះបង្កើតណាពី មូហាំម៉ាត់មកនោះគឺដើម្បីអំពាវនាវទៅរកភាពត្រឹមត្រូវនៃអ៊ីស្លាមនេះឯង ហើយអល់ឡោះបានបញ្ជាក់យ៉ាងច្បាស់ថា ពិតប្រាកដអ្នកណា ហើយដើរតាមគេ (ណាពីមូហាំម៉ាត់) អ្នកនោះឯងនឹងបានទទួលការចង្អុលបង្ហាញពី អល់ឡោះ តែអ្នកណាហើយប្រឆាំងមិនព្រមដើរតាមណាពីមូហាំម៉ាត់អ្នកនោះនឹងធ្លាក់ទៅក្នុងផ្លូវវង្វេងដ៏ជាក់ស្តែង។ អល់ឡោះបានក្រើនរំលឹកនៅក្នុងអាយ៉ាត់ៗដ៏ច្រើនដែលបញ្ជាក់ពីមូលហេតុធ្វើអោយប្រាសចាកចេញពីអ៊ីស្លាម និងប្រការដ៏ច្រើនដែលធ្វើអោយធ្លាក់ទៅក្នុងស៊ីរិក និងកាហ្វៀរ ហើយដូច្នេះដែរទេស្សនវិទូអ៊ីស្លាមជាច្រើនក៏បានបញ្ជាក់នៅក្នុងជំពូក (باب حكم المرتـد) ច្បាប់អ្នកដែលចេញពីអ៊ីស្លាមដែរ។ ពិតប្រាកដហើយអ្នកមូស្លីមជួនកាលគេអាចក្លាយជាអ្នកចេញពីអ៊ីស្លាមដោយប្រការ១ ពើ តាល់ជាច្រើនប្រភេទជាហេតុធ្វើអោយហាឡាល់ជីវិតរបស់គេ និងទ្រព្យសម្បត្តិរបស់គេហើយខ្លួនគេនោះទៀតសោតគឺស្ថិតនៅខាងក្រៅនៃអ៊ីស្លាម។ ប្រការ១ដែលធ្វើអោយពើតាល់អ៊ីស្លាមនោះគឺមានច្រើន ហើយគ្រោះថ្នាក់បំផុតនោះគឺនៅលើ១០ប្រការនេះ



ដែលយើងខ្ញុំនឹងរំលឹកវាដោយសង្ខេបដូចខាងក្រោម:-

**ប្រការ១**:ស៊ីរិកក្នុងការគោរពបូជាអ្វីមួយរួមនឹងអល់ឡោះ ដូចអល់ឡោះមានព្រះបន្ទូលថា:

(إن الله لا يغفر أن يشرك به ويغفر ما دون ذلك لمن يشاء)

មានន័យថា: ពិតប្រាកដអល់ឡោះមិនអាចលើកលែងទោសបានទេចំពោះអ្នកដែលស៊ីរិកនឹងអល់ឡោះនោះ។ តែអល់ឡោះអាចលើកលែងទោសអោយបានចំពោះអំពើបាបណា ដែលក្រៅពីស៊ីរិកចំពោះអ្នកណាដែលអល់ឡោះចង់លើកលែងទោសអោយ។ ដូចអល់ឡោះបានមានព្រះបន្ទូលនៅក្នុងអាយ៉ាត់ផ្សេងទៀតថា:

(إنه من يشرك بالله فقد حرم الله عن الجنة ومأواه النار وما للظالمين من أنصار) سورة المائدة الآية : 72

តាមពិតអ្នកណាដែលសាងអំពើស៊ីរិកនឹងអល់ឡោះ ពិតប្រាកដអល់ឡោះហាមផ្តាច់ខ្លួនគេចំពោះឋានសួគ៌ ហើយទីកន្លែងរបស់គេនោះគឺឋាននរកហើយគ្មានអ្នកណាអាចជួយចំពោះអ្នកដែលហ្សាលីមនេះបានឡើយ។ ការដែលបួងសួងសុំពីអ្នកដែលស្លាប់ទៅ ហើយក៏ត្រូវបានចាត់ទុកជាអំពើស៊ីរិកដែរដូចជាសុំអោយខ្មោចទាំងនោះជួយពួកគេ និងសំឡេះសត្វ ដើម្បីបូជាជូនខ្មោចទាំងនោះ។

**ប្រការ២**: បង្កើតខ្សែរយ:រវាងគេនឹងអល់ឡោះ ហើយគេបួងសួងសុំជំនួយតាមរយ:នោះឯងឬគេប្រគល់ក្តីរំពឹង ឬក្តីសង្ឃឹមក៏លើរយ:របស់គេ

នោះដែរ ។ អំពើរបៀបនេះគេនឹងក្លាយទៅជាកាហ្វេរ ដោយគ្មានការខ្វែងយោបល់គ្នាឡើយ ។

**ប្រការ៣:** អ្នកដែលមិនព្រមចាត់ទុកពពួកដែលសាងអំពើស៊ីរិកថា ជាកាហ្វេរ ឬគេមន្ទិលសង្ស័យក្នុងរឿងនេះ ឬគេថាអំពើស៊ីរិកនេះជាអំពើមួយដែលត្រឹមត្រូវតាមនិកាយ(مذهب)របស់ពួកគេនោះពួកទាំងនេះក៏ធ្វើអោយគេក្លាយជាកាហ្វេរដែរ ។

**ប្រការ៤:** អ្នកដែលជឿជាក់ថាក្រៅពីណាពីមូហាំម៉ាត់នៅមានណាពីផ្សេងទៀតអាចនាំការចង្អុលបង្ហាញ ឬបំពេញនូវការខ្វះខាតនៃការចង្អុលបង្ហាញរបស់ណាពី មូហាំម៉ាត់ដែលមិនទាន់បានផ្សព្វផ្សាយអោយបានគ្រប់គ្រាន់នៅឡើយ ឬគេថាច្បាប់អ្នកផ្សេងនោះប្រសើរជាងច្បាប់ដែលនាំមកដោយណាពីមូហាំម៉ាត់អ្នកនោះក៏ក្លាយជាកាហ្វេរដែរ ។

**ប្រការ៥:** អ្នកដែលបណ្ដុះបង្អាប់ប្រការណាមួយដែលរ៉ស៊ូលុលឡោះបានផ្ដល់មកសូម្បីគេបានប្រព្រឹត្តិ ប្រការនោះ ក៏ដោយក៏គេក្លាយជាកាហ្វេរដែរ ។ ជាក់ស្ដែងដូចអល់ឡោះ បានមានព្រះបន្ទូលថា:

(ذلك بأنهم كرهوا ما أنزل الله فأحبط أعمالهم) سورة محمد: 9

មានន័យថា: ពិតប្រាកដ ហើយពួកដែលស្អប់ខ្ពើមអ្វីៗដែលអល់ឡោះបានបញ្ចុះមកនោះគឺអល់ឡោះនឹងបដិសេធនូវអំពើល្អ របស់ពួកគេដែលបានសាងមកទាំងអស់ ។

**ប្រការ៦:** អ្នកណាហើយយកសាសនារបស់អល់ឡោះ ឬយកអំពើផលបុណ្យឬការដាក់ទណ្ឌកម្មដែលមាននៅក្នុងសាសនាធ្វើជាការចំអកលេងសើចគេនោះនឹងក្លាយជាកាហ្វេរដ៏ជាក់ច្បាស់ ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា: (قل أبالله وأياته ورسوله كنتم تستهزؤن)

មានន័យថា: ចូរពោលទៅកាន់ពួកគេចុះឱ!មូហាំម៉ាត់ តើជាមួយអល់ឡោះនិងអាយ៉ាត់ៗរបស់អល់ឡោះ ព្រមទាំងរ៉ស៊ូលរបស់ទ្រង់ពួកឯងយកមកធ្វើជាការលេងសើចឬ?

**ប្រការ៧:** ការប្រើវិជ្ជាមន្តអាគមដាក់អោយប្ដីប្រពន្ធដែលស្រឡាញ់គ្នាបែរជាស្អប់គ្នាទៅវិញឬក៏គេប្រើមន្តអគមធ្វើអ្វីម្យ៉ាងដែលមនុស្សមើលទៅចំឡែកដូចជាប្រើមន្តអាគមបំភាន់ភ្នែកតាមផ្លូវបិសាច ។ អ្នកប្រព្រឹត្តិឬ យល់ព្រមដូច្នេះក៏ក្លាយជាកាហ្វេរដែរ ។

**ប្រការ៨:** ការលើកស្ទួយ និងជួយគាំទ្រចំពោះអ្នកកាហ្វេរ លើអ្នកអ៊ីស្លាមមានន័យថាបោះបង់អ្នក អ៊ីស្លាមទៅជួយអ្នកកាហ្វេរករណីទាំងនេះក៏ធ្វើអោយខូចអ៊ីស្លាមរបស់គេដែរ ។ ដូចអល់បានមានព្រះបន្ទូលថា:

(ومن يتولهم منكم فإنه منهم إن الله لايهدي القوم الظالم)

មានន័យថា: អ្នណាហើយស្រឡាញ់គាំទ្រចំពោះអ្នកកាហ្វេរ ពិតប្រាកដគេនោះគឺស្ថិតក្នុងចំនោមកាហ្វេរនោះដែរ ។ តាមពិតអល់ឡោះមិនចង្អុលបង្ហាញពួកកាហ្វេរនោះឡើយ ។

**ប្រការ៩:** អ្នកដែលជឿជាក់ថាពិតប្រាកដមនុស្សខ្លះនោះអាចស្វែងរកផ្លូវផ្សេងដើរខាងក្រៅវង្វង់នៃមាគ៌ារបស់ណាពីមូហាំម៉ាត់ គេនោះគឺជាអ្នកកាហ្វេរដែរ ។ ដូចអល់ឡោះបានមានព្រះបន្ទូលថា:

( ومن يبتغ غير الإسلام دينا فلن يقبل من وهو في الآخرة من الخاسرين ) آل عمران :85

មានន័យថាៈ នរណាហើយស្វែងរកផ្សេងក្រៅពីអ៊ីស្លាមនោះធ្វើជាសាសនាពិតហើយ គេមិនទទួលស្គាល់ទេអ្វីដែលគេខំស្វែងរកនោះដល់ថ្ងៃបរលោក គេនោះនឹងស្ថិតក្នុងចំនោមពួកអ្នកដែលខាតបង់យ៉ាងពិតប្រាកដ ។

**ប្រការ១០:** ប្រឆាំងនឹងសាសនាអល់ឡោះហើយមិនព្រមស្វែងយល់ និងអនុវត្តតាមសាសនាអល់ឡោះ ។ រាល់ប្រការដែលបានលើកឡើងខាងលើនេះ វាជាប្រការដែលគ្រោះថ្នាក់ខ្លាំងក្លាជាទីបំផុតសំរាប់សាសនាអ៊ីស្លាម ហើយភាគច្រើនដែលធ្លាក់ខ្លួនទៅក្នុងប្រការ៧ទាំងនេះ ។

គួរអ្នកអ៊ីស្លាមត្រូវខ្លាច និងប្រុងប្រយ័ត្នពីការធ្លាក់ទៅក្នុងប្រការទាំងអស់នេះគេរាប់បញ្ចូលទៅក្នុងប្រការ ៤ដែរចំពោះអ្នកដែលជឿជាក់ថាច្បាប់ទំលាប់ដែលមនុស្សរៀបចំតាក់តែង ឡើងអាចប្រសើរជាងមាគ៌ារបស់អ៊ីស្លាម

❋ឬថាក្រិតក្រមនៃរបបអ៊ីស្លាម មិនអាចមានប្រសិទ្ធភាពក្នុងការអនុវត្តនៅសតវត្សទី២០នេះឡើយ ។

❋ឬជាហេតុធ្វើឱ្យអ្នកអ៊ីស្លាមមិនអាចជឿនលឿនទាន់សម័យបាន ។

❋ឬក៏ថាដោយសារការរឹតត្បិតរបស់សាសនា ចំពោះបុគ្គលនោះជាហេតុធ្វើអោយគេ មិនអាចប្រឡូកខ្លួនក្នុងកិច្ចការរស់នៅនៃមជ្ឈដ្ឋានខាងក្រៅបាន ។ ដូចគ្នានេះដែរចំពោះអ្នកដែលយល់ថាការសំរេចច្បាប់របស់អល់ឡោះដូចជាកាត់ដៃចំពោះចោរលួច ឬពិន័យដាក់ទណ្ឌកម្មចំពោះអ្នកដែលរួមរ័ក្សដោយមិនបានរៀបការ មិនមែនកំលោះក្រមុំរហូតទាល់តែស្លាប់ដោយចោទថាមិនសមយកមកអនុវត្តក្នុងសម័យជឿនលឿន ឬសម័យបច្ចុប្បន្ននេះបានទេ ។



❋អាចចូលនៅក្នុងប្រការ៤នោះទៀតរាល់អ្នកដែលជឿថាតាមពិតគេអាចកំណត់ច្បាប់សាសនាបានក្រៅពីច្បាប់របស់អល់ឡោះ ទោះជាគេយល់ថាមិនប្រសើរជាងច្បាប់អល់ឡោះក៏ដោយក៏ការកាត់ក្តី និងការងារផ្សេងៗព្រោះនេះវាធ្លាក់នៅក្នុងន័យថាៈ សំរេចថាហាឡាល(حلال)នូវអ្វីដែលអល់ឡោះបានកំណត់ថាហារ៉ម (حرام) ដូចគេសំរេចថា គ្មានបញ្ហាចំពោះប្រការដែលអល់ឡោះកំនត់ថាហារ៉ម ហើយត្រូវគេទទួលស្គាល់នៅក្នុងសាសនា ដូចជា ស៊ីណា ផឹកស្រា កេងប្រវ័ញ្ចចំពោះអ្នកដែល ជឿជាក់ថាធ្វើរបៀបនេះបានអ្នកនោះនឹងក្លាយទៅជាកាហ្វៀរ ដោយឯកភាពរវាងសាសនវិទូទាំងអស់ ។

نعوذ بالله من موجبات غضبه وأليم عقابه وصلى الله على خير خلقه محمد

على آله وصحبه وسلم.